# ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី STANISLAUS

# គម្រោងអភិបាលកិច្ចការបោះឆ្នោត ខែមករា ឆ្នាំ 2022

Donna Linder
ការិយាល័យ/ស្មៀនចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus
1021 “I” Street
Modesto, CA 95354
stanvote@stancounty.com
លេខទូរសព្ទឥតគិតថ្លៃ៖ (833) 772-2260
TTY៖ (833) 646-2136
www.stanvote.com

## សេចក្តីសង្ខេបប្រតិបត្តិ

ក្នុងឆ្នាំ 2016 រដ្ឋ California បានធ្វើការផ្លាស់ប្តូរជាប្រវត្តិសាស្ត្រក្នុងច្បាប់បោះឆ្នោត តាមរយៈការអនុម័តសេចក្តីព្រាងច្បាប់របស់ព្រឹទ្ធសភាលេខ 450, ក្រឹត្យជម្រើសរបស់អ្នកបោះឆ្នោត (Voter’s Choice Act, VCA) ។ ចាប់ផ្តើមនៅក្នុងឆ្នាំ 2018 VCA បានអនុញ្ញាតឱ្យខោនធីចំនួន 14 សាកល្បងកម្មវិធីដែលមានគោលដៅក្នុងការធ្វើឱ្យការបោះឆ្នោតកាន់តែអាចប្រើប្រាស់បាន និងកាន់តែងាយស្រួលសម្រាប់អ្នកបោះឆ្នោតដែលមានលក្ខណសម្បត្តិ។ ក្រោមគំរូរបស់ VCA មន្ត្រីបោះឆ្នោតត្រូវបានតម្រូវឱ្យផ្ញើសន្លឹកឆ្នោតតាមសំបុត្រទៅអ្នកបោះឆ្នោតដែលបានចុះបញ្ជីសកម្មទាំអស់ នៅរយៈពេល 29 ថ្ងៃមុនថ្ងៃបោះឆ្នោត។ បន្ទាប់មក អ្នកបោះឆ្នោតមានជម្រើសក្នុងការផ្ញើសំបុត្រឆ្នោតត្រឡប់មកវិញតាមសំបុត្រ នៅប្រអប់ទម្លាក់សន្លឹកឆ្នោតដែលមានការអនុញ្ញាត ឬដោយផ្ទាល់នៅការិយាល័យធំ ឬមជ្ឈមណ្ឌលបោះឆ្នោត។ មជ្ឈមណ្ឌលបោះឆ្នោតផ្តល់ជូនជម្រើសបោះឆ្នោតដោយផ្ទាល់ដែលស្រដៀងនឹងកន្លែងបោះឆ្នោត ប៉ុន្តែត្រូវបានបើករយៈពេលពីបួនទៅដប់ថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ដោយមានសមត្ថភាពក្នុងការផ្តល់ជូននូវការគាំទ្រកាន់តែច្រើនដល់អ្នកបោះឆ្នោត។ ក្រឹត្យជម្រើសរបស់អ្នកបោះឆ្នោតពង្រីកជម្រើសទីកន្លែងនិងពេលវេលាក្នុងការបោះឆ្នោតរបស់អ្នកបោះឆ្នោត ដែលចាំបាច់សម្រាប់របៀបរស់នៅដ៏មមាញឹកនាពេលបច្ចុប្បន្ន។ ការផ្លាស់ប្តូរផ្នែកនីតិបញ្ញត្តិ និងនិន្នាការថ្មីៗចំពោះឥរិយាបថអ្នកបោះឆ្នោតរបស់ខោនធី Stanislaus បានទាមទារឱ្យមានការផ្លាស់ប្តូរជាផ្លូវការទៅកាន់គំរូក្រឹត្យVCA។

ក្នុងឆ្នាំ 2020 ដោយសារតែការរាតត្បាតនៃវីរុសកូរ៉ូណា ច្បាប់ក្នុងគ្រាអាសន្នត្រូវបានអនុម័ត រួមទាំងសេចក្តីព្រាងច្បាប់របស់សភាលេខ 860 (Assembly Bill 860, AB 860) និងសេចក្តីព្រាងច្បាប់របស់ព្រឹទ្ធសភា (SB 423) ដើម្បីជួយបន្ថយការរីករាលដាលនៃវីរុសដោយការជំរុញការបោះឆ្នោតតាមរយៈសំបុត្រ និងដើម្បីជួយមន្ត្រីបោះឆ្នោតដែលប្រឈមនឹងបញ្ហាក្នុងការស្វែងរកចំនួនកន្លែងបោះឆ្នោត និងបុគ្គលិកបោះឆ្នោតបានគ្រប់គ្រាន់សម្រាប់ការបោះឆ្នោតទូទៅឆ្នាំ 2020។ ការរួមបញ្ចូលគ្នារវាង AB 860 និង SB 423 អនុញ្ញាតឱ្យខោនធីដែលមិនអនុម័ត VCA ដំណើរការការបោះឆ្នោតរបស់ពួកគេបានយ៉ាងស្រដៀងគ្នា។ AB 860 តម្រូវឱ្យមន្ត្រីបោះឆ្នោតផ្ញើសន្លឹកឆ្នោតតាមសំបុត្រទៅអ្នកបោះឆ្នោតដែលបានចុះបញ្ជីសកម្មទាំងអស់ ខណៈពេល SB 423 អនុញ្ញាតឱ្យខោនធីរួមបញ្ចូលកន្លែងបោះឆ្នោត និងតម្រូវឱ្យកន្លែងទាំងនេះបើករហូតដល់ទៅ 3 ថ្ងៃមុនថ្ងៃបោះឆ្នោត និងរហូតផុតថ្ងៃបោះឆ្នោត។ ដោយសារតែចំនួនមន្ត្រីរៀបចំការបោះឆ្នោតមានកំណត់ និងមានកន្លែងបោះឆ្នោតបែបប្រពៃណី ខោនធី Stanislaus បានភ្ជាប់កន្លែងប្រអប់ទម្លាក់សន្លឹកឆ្នោតចំនួន 12 និងបានបើក "ការិយាល័យរណប" ចំនួន 26 ដែលអនុញ្ញាតឱ្យអ្នកបោះឆ្នោតមានជម្រើសក្នុងការបោះឆ្នោតមុនពេលកំណត់ដោយផ្ទាល់សម្រាប់ការបោះឆ្នោតទូទៅឆ្នាំ 2020។ Senate Bill 423, SB 423 ក៏បានរួមបញ្ចូលលក្ខខណ្ឌតម្រូវក្នុងការផ្តល់ជូននូវឧបករណ៍គូសសន្លឹកឆ្នោតដែលអាចប្រើប្រាស់បានចំនួនបីផងដែរ។ ដើម្បីគោរពតាមលក្ខខណ្ឌតម្រូវ ខោនធី Stanislaus ត្រូវបានតម្រូវឱ្យកែប្រែសម្ភារដែលមានស្រាប់ទៅជាឧបករណ៍គូសសន្លឹកឆ្នោតដែលអាចប្រើប្រាស់បានដែលនាំឱ្យទទួលបានអត្ថប្រយោជន៍ផងដែរ ដើម្បីធ្វើឱ្យការបោះឆ្នោតកាន់តែងាយស្រួលសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព។

លើសពីនេះ នៅក្នុងការរៀបចំសម្រាប់ការបោះឆ្នោតដកតំណែងអភិបាលរដ្ឋ California ដែលធ្វើឡើងនៅថ្ងៃទី 14 ខែកញ្ញា ឆ្នាំ 2021 សេចក្តីព្រាងច្បាប់របស់សភាលេខ 152 ត្រូវបានអនុម័ត ដោយអនុញ្ញាតឱ្យបណ្តាខោនធីនានា រៀបចំការបោះឆ្នោតដកតំណែងអភិបាលរដ្ឋ California ស្រដៀងនឹងគំរូ VCA ដែរ។ អ្នកដែលបានចុះឈ្មោះសកម្មទាំងអស់ទទួលបានសន្លឹកឆ្នោតមួយសន្លឹកដែលគេផ្ញើឱ្យ។ បន្ទាប់មក អ្នកបោះឆ្នោតជ្រើសរើសប្រគល់សន្លឹកឆ្នោតមកវិញតាមប្រៃសណីយ៍ នៅប្រអប់ដាក់សន្លឹកឆ្នោត ឬទៅកាន់មណ្ឌលបោះឆ្នោតដើម្បីបោះឆ្នោតផ្ទាល់។ បន្ទាប់មក

នៅថ្ងៃទី 27 ខែកញ្ញា ឆ្នាំ 2021 សេចក្តីព្រាងច្បាប់របស់សភាលេខ 37 បានធ្វើវិសោធនកម្មក្រមបោះឆ្នោតលេខ 3000.5 ដោយបង្កើតលក្ខខណ្ឌតម្រូវឱ្យគ្រប់ខោនធីទាំងអស់ផ្ញើសន្លឹកឆ្នោតទៅកាន់អ្នកបោះឆ្នោតដែលបានចុះឈ្មោះសកម្មសម្រាប់ការបោះឆ្នោតនាពេលខាងមុខទាំងអស់។ ខោនធី Stanislaus នឹងបន្តមានមណ្ឌលបោះឆ្នោតដើម្បីជាជម្រើសសម្រាប់អ្នកបោះឆ្នោតក្នុងការទៅបោះឆ្នោតដោយផ្ទាល់ដើម្បីជាជម្រើសជំនួសផ្សេងមួយសម្រាប់ការផ្ញើសន្លឹកឆ្នោតរបស់ពួកគេតាមសំបុត្រ។

នៅក្នុងខោនធី Stanislaus ការិយាល័យមន្ត្រីចុះបញ្ជីបោះឆ្នោតអនុវត្តការបោះឆ្នោតដោយសេចក្តីសុចរិតលទ្ធភាពប្រើប្រាស់ តម្លាភាព និងការប្រើប្រាស់ធនធានរបស់អ្នកបង់ពន្ធយ៉ាងមានប្រសិទ្ធភាព។ ដោយមានគុណតម្លៃនេះនៅក្នុងចិត្ត ខោនទី Stanislaus កំពុងធ្វើឲ្យទំនើបនូវម៉ូដែលបោះឆ្នោតរបស់ខ្លួនដោយអនុម័តក្រឹត្យជម្រើសរបស់អ្នកបោះឆ្នោត។ នៅក្នុងការសម្រេចនេះការិយាល័យចុះឈ្មោះនៃការិយាល័យបោះឆ្នោតបានពិនិត្យមើលជោគជ័យនៃការបោះឆ្នោតទូទៅកាលពីឆ្នាំ 2020 គួរផ្សំនឹងចំនួនអ្នកបោះឆ្នោតដែលកើនឡើង និងនិន្នាការរបស់ពួកគេព្រមទាំងការវាយតម្លៃលើធនធានបច្ចុប្បន្នរបស់នាយកដ្ឋាន។ នៅក្នុងការបោះឆ្នោតប្រធានាធិបតីកាលពីឆ្នាំ 2020 អ្នកបោះឆ្នោត 77% នៅក្នុងខោនធី Stanislaus បានចុះឈ្មោះរួចរាល់ដើម្បីបោះឆ្នោតតាមសំបុត្រ។  ក្នុងចំណោមអ្នកបោះឆ្នោត 77.76% ដែលបានចូលរួមនៅក្នុងការបោះឆ្នោតប្រធានាធិបតីកាលពីឆ្នាំ 2020 អ្នកបោះឆ្នោតជិត 37% បានទម្លាក់សន្លឹកឆ្នោតនៅកន្លែងប្រអប់សំបុត្រដែលមានបុគ្គលិកឬគ្មានបុគ្គលិកបម្រើការ។ ដោយសារតែការបំប្លែងនៃឧបករណ៍បោះឆ្នោតដែលអាចចូលប្រើបាននៅលើឧបករណ៍គូសលើសន្លឹកឆ្នោត សន្និធិឧបករណ៍បច្ចុប្បន្នរបស់ខោនធី Stanislaus បំពេញតម្រូវការនៃក្រឹត្យជម្រើសរបស់អ្នកបោះឆ្នោត។

ការអនុម័តនៃក្រឹត្យជម្រើសរបស់អ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងផ្តល់ដល់អ្នកបោះឆ្នោតនូវជម្រើសកាន់តែច្រើនអំពីរបៀប ពេលវេលា និងទីកន្លែងដែលពួកគេបោះឆ្នោត។ អ្នកបោះឆ្នោតនឹងមានជម្រើសដើម្បីទៅទីតាំងមជ្ឈមណ្ឌលបោះឆ្នោត *ណាមួយក៏បាន* នៅក្នុងខោនធីទាំងមូល។ ដោយចំនួនអ្នកបោះឆ្នោតដែលបានចុះឈ្មោះបច្ចុប្បន្នមានចំនួន 282,482 នាក់ គិតត្រឹមថ្ងៃទី 30 ខែសីហា ឆ្នាំ 2021 មជ្ឈមណ្ឌលបោះឆ្នោតប្រាំមួយនឹងបើកនៅ 10 ថ្ងៃមុនការបោះឆ្នោត និងយ៉ាងតិចម្ភៃបីមជ្ឈមណ្ឌលបន្ថែម សរុបយ៉ាងតិចម្ភៃប្រាំបួនមជ្ឈមណ្ឌលបោះឆ្នោត នឹងបើកនៅ 3 ថ្ងៃមុនថ្ងៃបោះឆ្នោត ពេញមួយថ្ងៃបោះឆ្នោត រួមទាំងចុងសប្តាហ៍។ អ្នកបោះឆ្នោតលែងត្រូវបានកំណត់ឲ្យបោះឆ្នោតបានតែនៅថ្ងៃបោះឆ្នោត នៅកន្លែងបោះឆ្នោតដែលបានកំណត់ទៀតហើយ។ មជ្ឈមណ្ឌលបោះឆ្នោតនឹងត្រូវមានប្រចាំការដោយបុគ្គលិកបោះឆ្នោតដែលមានការបណ្តុះបណ្តាល ដែលអាចផ្តល់សេវាកម្មច្រើនជាងកន្លែងបោះឆ្នោត។

អ្នកបោះឆ្នោតនៃខោនធី Stanislaus នឹងមានជម្រើសកាន់តែច្រើន។ ក្នុងការអនុវត្តតាមគោលដៅរបស់ការិយាល័យ យើងជឿថាការអនុវត្តតាមម៉ូដែលនេះ នឹងបង្កើនសុចរិតភាពនៃការបោះឆ្នោត លទ្ធភាពប្រើប្រាស់ និងការចេញមកបោះឆ្នោត។ ដើម្បីឲ្យខោនធី Stanislaus ផ្លាស់ប្តូរទៅប្រើម៉ូដែល VCA គម្រោងអភិបាលកិច្ចការបោះឆ្នោតនេះ (Election Administration Plan, EAP) ត្រូវបានបង្កើតឡើងដោយការិយាល័យរបស់យើង ដោយមានកិច្ចសហការជាមួយសហគមន៍របស់យើង។ ការិយាល័យចុះឈ្មោះបោះឆ្នោតបានធ្វើការជាមួយបុគ្គលដែលតំណាងឱ្យសហគមន៍ខាងភាសា និងអ្នកមានពិការភាព ហើយក៏បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈជាបន្តបន្ទាប់ដើម្បីប្រមូលមតិសាធារណៈដែលត្រូវបានអនុវត្តនៅក្នុងផែនការនេះ។ មុនពេលផែនការនេះត្រូវបានបញ្ជូនទៅការិយាល័យរដ្ឋលេខាធិការនៃរដ្ឋ Califronia ដើម្បីទទួលបានការអនុម័ត វាត្រូវបានបង្ហោះនៅលើគេហទំព័រ www.stanvote.com សម្រាប់ការពិនិត្យមើល និងផ្តល់មតិជាសាធារណៈ។ មតិកែលម្អ និងអនុសាសន៍ចំពោះផែនការនេះ ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងនាពេលអនាគតនឹងត្រូវបានទទួលយកនៅពេលណាក៏បាន។

EAP របស់យើងពណ៌នាអំពីរបៀបដែលយើងរៀបចំផែនការដើម្បីអប់រំដល់សាធារណៈជនពាក់ព័ន្ធនឹងជម្រើសដែលមាននៅក្នុងម៉ូដែល VCA។ វារួមមានព័ត៌មានអំពីមជ្ឈមណ្ឌលបោះឆ្នោតនិងទីតាំងទម្លាក់សន្លឹកឆ្នោតដែលបានស្នើសុំ និងរបៀបដែលវានឹងប្រតិបត្តិការ។ ជាមួយនឹង EAP នេះ យើងសង្ឃឹមថានឹងផ្តល់នូវគំនិតច្បាស់លាស់អំពីរបៀបដែលការិយាល័យរបស់យើងកំពុងរៀបចំផែនការគ្រប់គ្រងការបោះឆ្នោតនៅពេលអនាគតនៅក្នុងខោនធី Stanislaus ។

# មាតិកា


ជំពូក I - មជ្ឈមណ្ឌលបោះឆ្នោត ........ 1

ចំនួនមជ្ឈមណ្ឌលបោះឆ្នោតសរុបនឹងត្រូវរៀបចំឡើង ........ 1

ទីតាំងមជ្ឈមណ្ឌលបោះឆ្នោត ........ 1

ការដាក់បុគ្គលិកប្រចាំការនៅមជ្ឈមណ្ឌលបោះឆ្នោត ........ 3

ការរៀបចំ និងប្លង់នៃមជ្ឈមណ្ឌលបោះឆ្នោត ........ 3

ផែនការសន្តិសុខ និងត្រៀមបម្រុង ........ 3

វិធានការបង្ការ និងការរំខានដែលអាចកើតមាន ........ 5

ជំពូក II - ទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោត ........ 6

ម៉ោងនៃទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោត ........ 6

ចំនួនប្រអប់សរុបនឹងត្រូវកំណត់នៅពេលក្រោយ។ ........ 6

ទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោត ........ 6

ជំពូក III - ការកំណត់អត្តសញ្ញាណមជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោត ........ 7

ជំពូក IV - ការចំណាយ និងការសន្សំប្រាក់ដែលបានប៉ាន់ស្មា នសម្រាប់រយៈពេលខ្លី និងរយៈពេលវែង ........ 12

ការចំណាយ និងការសន្សំប្រាក់ដែលបានប៉ាន់ស្មាននៅក្រោ មផែនការនេះ ........ 12

ជំពូក V -ការអប់រំ និងការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត – ទូទៅ ........ 13

ប្រព័ន្ធផ្សព្វផ្សាយ និងការប្រកាសអំពីសេវាកម្មសាធារណៈ ........ 13

ការមានវត្តមាននៃសហគមន៍ ........ 14

ការទាក់ទងទៅអ្នកបោះឆ្នោតដោយផ្ទាល់ ........ 15

វិបសាយរបស់ការិយាល័យចុះបញ្ជីអ្នកបោះឆ្នោតនៅខោនធី Stanislaus ........ 15

ការប្រើប្រាស់ធនធានដើម្បីធានាថា អ្នកបោះឆ្នោតត្រូវបានជូនដំណឹង ........ 15

ជំពូក VI-ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី STANISLAUS - ការអប់រំ និងការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត –អ្នកបោះឆ្នោតដែល មានតម្រូវការក្នុងការចេញចូល ........ 16

ការអប់រំសហគមន៍ជនពិការ– សិក្ខាសាលាអប់រំអ្នកបោះឆ្នោត ........ 16

សម្ភារបោះឆ្នោត និងសន្លឹកឆ្នោតសម្រាប់ជនពិការ និងវិបសាយសម្រាប់ជនពិការ ........ 17

សេវាកម្មសម្រាប់ជនពិការដែលអាចប្រើប្រាស់បាននៅមជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោត ........ 17

ការស្នើសុំសន្លឹកឆ្នោតបោះតាមសំបុត្រសម្រាប់ជនពិការ ........ 18

ការស្នើសុំសន្លឹកឆ្នោតជំនួស ........ 18

ទូរសព្ទឥតគិតថ្លៃសម្រាប់អ្នកបោះឆ្នោតថ្លង់ ឬស្តាប់មិនសូវឮ ........ 19

ការដោះស្រាយកម្លាតក្នុងពិការភាពរបស់អ្នកបោះឆ្នោត និងការចូលរួម ........ 19

**ជំពូក VII - ការអប់រំ និងការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត – សហគមន៍ជនជាតិភាគតិចផ្នែកភាសា** 20
ការអប់រំសហគមន៍ជនជាតិភាគតិចផ្នែកភាសា - សិក្ខាសាលាអប់រំអ្នកបោះឆ្នោត 20
កិច្ចប្រជុំពិគ្រោះយោបល់សាធារណៈ 21
ប្រព័ន្ធផ្សព្វផ្សាយ និងការប្រកាសអំពីសេវាកម្មសាធារណៈ 21
ជំនួយតាមទូរសព្ទបន្ទាន់ឥតគិតថ្លៃសម្រាប់អ្នកបោះឆ្នោត 22
សម្ភារអប់រំជាភាសាអេស្ប៉ាញ 22
ជំនួយផ្នែកភាសាមាននៅមជ្ឈមណ្ឌលបោះឆ្នោត 22
ការស្នើសុំសន្លឹកឆ្នោតទូរសារភាសាភាគតិច 23
ការកំណត់អត្តសញ្ញាណអ្នកបោះឆ្នោតភាគតិចផ្នែកភាសា 23
**ឧបសម្ព័ន្ធ** 24
ឧបសម្ព័ន្ធ A 25
ឧបសម្ព័ន្ធ B 28
ឧបសម្ព័ន្ធ C 29
ឧបសម្ព័ន្ធ D 30
ឧបសម្ព័ន្ធ E 31

## ជំពូក I - មជ្ឈមណ្ឌលបោះឆ្នោត

នៅមជ្ឈមណ្ឌលបោះឆ្នោត បុគ្គលម្នាក់ៗអាចទទួលសេវាកម្មដូចខាងក្រោមៈ

- បោះឆ្នោតដោយផ្ទាល់
- ចុះឈ្មោះសម្រាប់លើកដំបូង និងទទួលសន្លឹកឆ្នោតដោយមិនចាំបាច់បោះឆ្នោតបណ្ដោះអាសន្ន
- ធ្វើបច្ចុប្បន្នភាពការចុះឈ្មោះអ្នកបោះឆ្នោតបច្ចុប្បន្ន និងទទួលសន្លឹកឆ្នោត
- ប្រើប្រាស់ឧបករណ៍គូសសន្លឹកឆ្នោតសម្រាប់ជនពិការ
- មកទទួលសន្លឹកឆ្នោតសម្រាប់សមាជិករស់ក្នុងខ្ទង់ផ្ទះតែមួយ ឬសមាជិកគ្រួសារ
- ស្នើសុំសន្លឹកឆ្នោតទូរសារ (សំណៅបកប្រែនៃសន្លឹកឆ្នោតផ្លូវការ) ជាភាសាអាសារៀន ខ្មែរ និងពុនចាប៊ី
- ទម្លាក់សន្លឹកឆ្នោតដែលបានបំពេញរួចនៅមជ្ឈមណ្ឌលបោះឆ្នោត

### ចំនួនមជ្ឈមណ្ឌលបោះឆ្នោតសរុបនឹងត្រូវរៀបចំឡើង

§4005(a)(10)(I)(vi)(I)

ផ្តោតលើចំនួននៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងបង្កើតយ៉ាងហោចណាស់ 6 មជ្ឈមណ្ឌលបោះឆ្នោតសម្រាប់រយៈពេល 10 ថ្ងៃ មុនថ្ងៃបោះឆ្នោត និង 23 មជ្ឈមណ្ឌលបោះឆ្នោតបន្ថែមបើកនៅ 3 ថ្ងៃ មុន និងថ្ងៃបោះឆ្នោត។ គោលដៅគឺត្រូវផ្តល់មជ្ឈមណ្ឌលបោះឆ្នោតរហូតដល់ 30 កន្លែង ដែលលើសពីលក្ខខណ្ឌតម្រូវក្នុង SB 450 និងការចុះឈ្មោះអ្នកបោះឆ្នោតបច្ចុប្បន្នរបស់ខោនធី។

មជ្ឈមណ្ឌលបោះឆ្នោតទាំងអស់នឹងបើកយ៉ាងហោចណាស់ 8 ម៉ោងក្នុងមួយថ្ងៃ។ នៅថ្ងៃបោះឆ្នោត គ្រប់មជ្ឈមណ្ឌលបោះឆ្នោតនឹងបើកពីម៉ោង 7:00 ព្រឹករហូតដល់ 8:00 យប់។ ម៉ោងពិតប្រាកដនៃប្រតិបត្តិការរបស់មជ្ឈមណ្ឌលបោះឆ្នោតនីមួយៗ នឹងត្រូវបានផ្សាយនៅលើវិបសាយរបស់ការិយាល័យចុះឈ្មោះបោះឆ្នោតនៅខោនធី Stanislaus www.stanvote.com និងរួមបញ្ចូលនៅក្នុងមគ្គុទេសក៍សម្រាប់ព័ត៌មានអ្នកបោះឆ្នោតនៅខោនធី Stanislaus ។

### ទីតាំងមជ្ឈមណ្ឌលបោះឆ្នោត

§4005(a)(10)(I)(vi)(I)

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus កំពុងធ្វើការនៅក្នុងសហគមន៍ទាំងមូលដើម្បីកំណត់អត្តសញ្ញាណមជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោតដែលបំពេញលក្ខណវិនិច្ឆ័យរៀបរាប់នៅក្នុងផ្នែកខាងក្រោម ដោយប្រើប្រាស់ទិន្នន័យដែលបានប្រមូលពីជំរឿនថ្មីៗបំផុតចុងក្រោយដែលមាន និងការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus បច្ចុប្បន្ន។

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus ដែលកំពុងប្រើប្រាស់ទិន្នន័យដែលបានប្រមូលពីជំរឿនថ្មីៗបំផុតចុងក្រោយដែលមាន ហើយការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus បច្ចុប្បន្នកំពុងធ្វើការនៅក្នុងសហគមន៍ទាំងមូលដើម្បីកំណត់អត្តសញ្ញាណមជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោតដែលបំពេញលក្ខណវិនិច្ឆ័យដែលមានរៀបរាប់ខាងក្រោម។

- មជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោត នៅជិតមធ្យោបាយធ្វើដំណើរសាធារណៈ។
- មជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោតនៅជិតសហគមន៍ដែលធ្លាប់មានចំនួនបោះឆ្នោតទាបតាមរយៈការប្រើប្រាស់សំបុត្រ។
- មជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោត នៅជិតមជ្ឈមណ្ឌលប្រជាជន។

- មជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោត នៅជិតសហគមន៍អ្នកជនជាតិភាគតិចខាងភាសា។
- មជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោត នៅជិតអ្នកបោះឆ្នោតដែលមានពិការភាព។
- មជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោត នៅជិតសហគមន៍ដែលមានអត្រាអ្នកកាន់កាប់យានយន្តលក្ខណៈគ្រួសារតិចតួច។
- មជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោត នៅជិតសហគមន៍ដែលមានចំណូលទាប។
- មជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោត នៅជិតសហគមន៍នៃអ្នកបោះឆ្នោតដែលមានសិទ្ធិបោះឆ្នោត ដែលមិនបានចុះឈ្មោះបោះឆ្នោត ហើយអាចត្រូវការសិទ្ធិចូលទៅចុះឈ្មោះអ្នកបោះឆ្នោតនៅថ្ងៃតែមួយ។
- មជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោត នៅជិតប្រជាជនដែលមានភូមិសាស្ត្រដាច់ស្រយាល រួមទាំងការបម្រុងទុកសម្រាប់ជនជាតិដើមអាមេរិក។
- សិទ្ធិចូលប្រើកន្លែងចតរថយន្តដែលអាចចូលប្រើបាន និងឥតគិតថ្លៃនៅមជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោត។
- ចម្ងាយ និងពេលវេលាដែលអ្នកបោះឆ្នោតត្រូវធ្វើដំណើរតាមរថយន្ត ឬមធ្យោបាយធ្វើដំណើរសាធារណៈទៅកាន់មជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោត។
- តម្រូវការសម្រាប់វិធីសាស្ត្រជំនួសនានាសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាពដែលបោះឆ្នោតតាមសំបុត្រមិនអាចចូលទៅបោះឆ្នោតបានទេ។
- លំនាំចរាចរណ៍នៅជិតមជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោត។
- តម្រូវការមជ្ឈមណ្ឌលបោះឆ្នោតចល័តបន្ថែមលើចំនួនមជ្ឈមណ្ឌលបោះឆ្នោតដែលបានបង្កើតឡើងស្របតាមផ្នែកនេះ។

ដំណើរការនៃការបង្កើតទីតាំងបន្តនៅឡើយរហូតដល់ពេលផ្សព្វផ្សាយផែនការនេះ។ គោលដៅរបស់ការិយាល័យចុះបញ្ជីអ្នកបោះឆ្នោតនៅខោនធី Stanislaus គឺដាក់ទីតាំងមជ្ឈមណ្ឌលបោះឆ្នោតនៅទីកន្លែងដែលងាយស្គាល់ និងងាយចេញចូល។ មជ្ឈមណ្ឌលបោះឆ្នោតទាំងអស់នឹងបន្តបើករយៈពេលយ៉ាងតិច 8 ម៉ោងក្នុងមួយថ្ងៃ ពីម៉ោង 7 ព្រឹកដល់ 8 យប់ នៅថ្ងៃបោះឆ្នោត។ ផ្អែកលើព័ត៌មានដែលមាននៅពេលនេះ គេរំពឹងថា មជ្ឈមណ្ឌលបោះឆ្នោតនឹងស្ថិតនៅទីតាំងដូចខាងក្រោម៖

ក្រុង Modesto
ក្រុង Ceres
ក្រុង Turlock
ក្រុង Oakdale
ក្រុង Newman
ក្រុង Paterson
ក្រុង Hughson
ក្រុង Riverbank
ក្រុង Waterford
សហគមន៍មិនបានរៀបរាប់នៅ Salida, Denair, Keyes និង Empire

ទីតាំងមជ្ឈមណ្ឌលបោះឆ្នោតដែលបានប្រើពីមុនត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ B។ បញ្ជីដែលបានធ្វើបច្ចុប្បន្នភាពដែលបង្ហាញពីទីតាំងមជ្ឈមណ្ឌលបោះឆ្នោតជាក់លាក់ចំពោះការបោះឆ្នោតបច្ចុប្បន្ននឹងត្រូវបានបង្ហោះនៅលើគេហទំព័រ stanvote.com។ ជាមួយគ្នានេះផងដែរ បញ្ជីនេះនឹងត្រូវបានបញ្ចូលក្នុងសំបុត្រផ្ទាល់ពីរដាច់ដោយឡែកពីគ្នាផ្ញើទៅកាន់អ្នកបោះឆ្នោត។

## ការដាក់បុគ្គលិកប្រចាំការនៅមជ្ឈមណ្ឌលបោះឆ្នោត

§4005(a)(10)(I)(vi)(IX)

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus សង្ឃឹមថាមជ្ឈមណ្ឌលបោះឆ្នោតនីមួយៗនឹងមានបុគ្គលិកប្រចាំការខាងស្មៀនរៀបចំការបោះឆ្នោតប្រហែលបីទៅប្រាំនាក់ រួមទាំងប្រធានមជ្ឈមណ្ឌលបោះឆ្នោត។ លើសពីនេះ មជ្ឈមណ្ឌលបោះឆ្នោតក៏នឹងមានដាក់អ្នកស្ម័គ្រចិត្តបន្ថែមផងដែរ។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនឹងខិតខំប្រឹងប្រែងដោយស្មោះត្រង់ក្នុងការជ្រើសរើសបុគ្គលិករៀបចំការបោះឆ្នោត និងអ្នកស្ម័គ្រចិត្តដែលចេះពីរភាសាជាភាសាអាសារៀន ខ្មែរ ពុនចាប៊ី ឬភាសាអេស្ប៉ាញដល់បុគ្គលិកនៅមជ្ឈមណ្ឌលបោះឆ្នោតនីមួយៗ ជាពិសេសនៅកន្លែងដែលបង្កើតនៅជិតសហគមន៍ភាសា។

ស្មៀនរៀបចំការបោះឆ្នោតនឹងទទួលការបណ្តុះបណ្តាលមុនការបោះឆ្នោតនីមួយៗ។ ស្មៀនរៀបចំការបោះឆ្នោតនឹងទទួលការបណ្តុះបណ្តាលជំនាញដោយប្រើប្រាស់ប្រព័ន្ធចុះឈ្មោះបោះឆ្នោតដែលប្រើនៅមជ្ឈមណ្ឌលបោះឆ្នោត និងឧបករណ៍បោះឆ្នោត។ វគ្គបណ្តុះបណ្តាលនេះនឹងគ្របដណ្តប់លើសេណារីយ៉ូផ្សេងៗ ដើម្បីឲ្យស្មៀនរៀបចំការបោះឆ្នោតមានចំណេះដឹងអំពីទម្រង់បែបបទត្រឹមត្រូវ និង/ឬស្រោមសំបុត្រដើម្បីចេញដល់អ្នកបោះឆ្នោត និងរបៀបដំណើរការកំណត់ត្រារបស់ពួកគេនៅក្នុងប្រព័ន្ធ។ ស្មៀនរៀបចំការបោះឆ្នោតក៏ត្រូវបានបណ្តុះបណ្តាលលើជំនាញផ្តល់សេវាកម្មដល់អតិថិជនកម្រិតមូលដ្ឋាន របៀបបង្កើតមជ្ឈមណ្ឌលបោះឆ្នោត នីតិវិធីបើកនិងបិទប្រចាំថ្ងៃ របៀបជួយអ្នកបោះឆ្នោតដែលមានពិការភាព និងរបៀបជួយអ្នកបោះឆ្នោតដែលមានតម្រូវការជំនួយផ្នែកភាសាផងដែរ។ ការណែនាំបន្ថែម និងនីតិវិធីជាលាយលក្ខណ៍អក្សរនឹងត្រូវបានផ្តល់ជូនដល់ស្មៀនរៀបចំបោះឆ្នោតនីមួយៗ ដើម្បីប្រើប្រាស់ជាឯកសារយោងនៅពេលធ្វើការនៅមជ្ឈមណ្ឌលបោះឆ្នោត។

អ្នកស្ម័គ្រចិត្តនឹងទទួលការបណ្តុះបណ្តាលដាច់ដោយឡែកពីស្មៀនរៀបចំការបោះឆ្នោតនៅមុនការបោះឆ្នោតនីមួយៗ។ អ្នកស្ម័គ្រចិត្តនឹងត្រូវបានបណ្តុះបណ្តាលលើជំនាញផ្តល់សេវាកម្មដល់អតិថិជនកម្រិតមូលដ្ឋាន នៅពេលដែលពួកគេត្រួតពិនិត្យការស្វាគមន៍ និងការគ្រប់គ្រងជួរនៅមណ្ឌលបោះឆ្នោត។ លើសពីនេះ ពួកគេនឹងទទួលបានវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីបើកនិងបិទប្រចាំថ្ងៃ រួមជាមួយនឹងការបណ្តុះបណ្តាលដោយមានការអនុវត្តផ្ទាល់ស្តីពីការរៀបចំ និងដកហូតឧបករណ៍បោះឆ្នោត។ អ្នកស្ម័គ្រចិត្តនឹងត្រូវបានបណ្តុះបណ្តាលអំពីរបៀបជួយអ្នកបោះឆ្នោតដែលមានពិការភាព និងរបៀបប្រើប្រាស់ Touch Writer ដែលជាឧបករណ៍គូសសន្លឹកឆ្នោតដែលអាចចូលប្រើបាន។ ពួកគេក៏នឹងទទួលបានការបណ្តុះបណ្តាលស្តីពីការជួយដល់អ្នកបោះឆ្នោត ដែលត្រូវការជំនួយផ្នែកភាសាផងដែរ។

## ការរៀបចំ និងប្លង់នៃមជ្ឈមណ្ឌលបោះឆ្នោត

§4005(a)(10)(I)(vi)(XI)

មជ្ឈមណ្ឌលបោះឆ្នោតនឹងត្រូវបានរៀបចំតាមរបៀបមួយដែលធានាថា អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះសន្លឹកឆ្នោតឯកជន និងឯករាជ្យ។ ឧបករណ៍បោះឆ្នោត និងប្រអប់ទម្លាក់សន្លឹកឆ្នោតនឹងត្រូវបានដាក់តាមលក្ខណៈយុទ្ធសាស្ត្រនៅក្នុងមជ្ឈមណ្ឌលបោះឆ្នោត ដើម្បីងាយរកឃើញដោយអ្នកបោះឆ្នោត និងអាចត្រួតពិនិត្យបានដោយបុគ្គលិកមជ្ឈមណ្ឌលបោះឆ្នោត។ សូមមើលឧបសម្ព័ន្ធ C សម្រាប់ការរៀបចំជាគំរូ និងប្លង់នៃមជ្ឈមណ្ឌលបោះឆ្នោត។

## ផែនការសន្តិសុខ និងត្រៀមបម្រុង

§4005(a)(10)(I)(vi)(VIII)

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងធានាសន្តិសុខនៃការបោះឆ្នោតនៅមជ្ឈមណ្ឌលបោះឆ្នោត ដោយប្រើប្រាស់វិធីសាស្ត្រនិងស្តង់ដារដូចខាងក្រោម៖

DRAFT

- បុគ្គលិកមជ្ឈមណ្ឌលបោះឆ្នោតទាំងអស់នឹងមានការបណ្តុះបណ្តាលត្រឹមត្រូវ និងបានត្រៀមខ្លួនរួចរាល់ដើម្បីជួយដល់អ្នកបោះឆ្នោតដែលមានសិទ្ធិតាមគ្រប់វិធីដែលអាចធ្វើបាន។ បុគ្គលិកមជ្ឈមណ្ឌលបោះឆ្នោតទាំងអស់នឹងយល់ដឹងច្បាស់អំពីខ្សែសង្វាក់នៃទម្រង់ការថែរក្សា និងប្រតិបត្តិការនៃឧបករណ៍បោះឆ្នោត។

- បុគ្គលិកមជ្ឈមណ្ឌលបោះឆ្នោតនឹងមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការបោះឆ្នោតតែមួយ (DIMS) ដែលបានប្រើប្រាស់នៅក្នុងការិយាល័យប្រចាំខោនធី។ ដើម្បីធានាថាអ្នកបោះឆ្នោតដែលមានសិទ្ធិបោះឆ្នោត ពួកគេមានសិទ្ធិចូលរួមក្នុងការបោះឆ្នោតនីមួយៗ នោះ DIMS អនុញ្ញាតឲ្យបុគ្គលិកមជ្ឈមណ្ឌលបោះឆ្នោតកំណត់ថាតើ អ្នកបោះឆ្នោតបានចុះឈ្មោះត្រឹមត្រូវឬទេ ថាតើអ្នកបោះឆ្នោតបានទទួលសន្លឹកឆ្នោតឬទេ ថាតើអ្នកបោះឆ្នោតបានប្រគល់សន្លឹកឆ្នោតឬទេ ហើយសន្លឹកឆ្នោតប្រភេទអ្វីដែលត្រូវផ្តល់ទៅអ្នកបោះឆ្នោត។

- រាល់លែបថប់ដែលបានភ្ជាប់ទៅនឹងប្រព័ន្ធគ្រប់គ្រងការបោះឆ្នោតក៏នឹងត្រូវបានភ្ជាប់ទៅនឹង VoteCal ដែលជាទិន្នន័យចុះបញ្ជីអ្នកបោះឆ្នោតទូទាំងរដ្ឋជាផ្លូវការ ដែលគ្រប់គ្រងដោយលេខារដ្ឋ California ។ VoteCal នឹងតាមដានអ្នកបោះឆ្នោតទូទាំងរដ្ឋ និងជូនដំណឹងដល់បុគ្គលិកមជ្ឈមណ្ឌលបោះឆ្នោត ប្រសិនបើអ្នកបោះឆ្នោតត្រូវបានចុះឈ្មោះសកម្មនៅក្នុងខោនធីមួយទៀត និងប្រសិនបើអ្នកបោះឆ្នោតបានទទួល និង/ឬបានប្រគល់សន្លឹកឆ្នោតនៅក្នុងខោនធីមួយទៀតរួចហើយ។

- គ្រប់ឧបករណ៍ដែលនឹងត្រូវបានភ្ជាប់ទៅនឹងប្រព័ន្ធគ្រប់គ្រងការបោះឆ្នោតនឹងត្រូវអនុវត្តពេញលេញតាមវិធានការ និងបទបញ្ញត្តិសន្តិសុខ (§20158) ដោយប្រើអង្គភាពព័ត៌មានវិទ្យារបស់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus ដើម្បីធានាថា សន្តិសុខត្រូវបានធានាគ្រប់ពេលវេលា។

- មជ្ឈមណ្ឌលបោះឆ្នោតនីមួយៗនឹងមានឧបករណ៍ ធនធាន និងសញ្ញាបិទនៅចំទីតាំងសំខាន់ៗ ដើម្បីធានាថា អ្នកបោះឆ្នោតទាំងអស់មានឱកាសបោះឆ្នោតដោយឯកជន និងឯករាជ្យ។

- ឧបករណ៍បោះឆ្នោត HART InterCivic Verity (Print, Touch Writer, និង Scan) ត្រូវបានបញ្ជាក់ដោយលេខារដ្ឋ California ។ វាជាប្រព័ន្ធប្រើក្រដាស ហើយមិនភ្ជាប់ទៅនឹងបណ្តាញណាមួយទេ។ រាល់ឧបករណ៍នឹងត្រូវបានបិទតែមផ្នែកបោះឆ្នោតផ្លូវការ ហើយនឹងត្រូវបិទ ចាក់សោនៅពេលមជ្ឈមណ្ឌលបោះឆ្នោតមិនបើក។

- រាល់ការបោះឆ្នោតដែលបានកត់ត្រា រួមមានសន្លឹកឆ្នោតក្រដាស សន្លឹកឆ្នោតដែលបានដាក់បញ្ចូនតាមឧបករណ៍បោះឆ្នោត សន្លឹកឆ្នោត ចុះឈ្មោះអ្នកបោះឆ្នោតតាមលក្ខខណ្ឌ សន្លឹកឆ្នោតបណ្តោះអាសន្ន និងសន្លឹកឆ្នោតបោះតាមសំបុត្រ នឹងត្រូវបានដឹកជញ្ជូនដោយសុវត្ថិភាពទៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus ជាប្រចាំថ្ងៃក្រោយពេលមជ្ឈមណ្ឌលបោះឆ្នោតបិទ។

DRAFT

## វិធានការបង្ការ និងការរំខានដែលអាចកើតមាន

§4005(a)(10)(I)(vi)(VIII)(ia), §4005(a)(10)(I)(vi)(VIII)(ib)

បុគ្គលិកបោះឆ្នោត និងបុគ្គលិកមជ្ឈមណ្ឌលបោះឆ្នោតនឹងត្រូវបានបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវ ហើយត្រៀមលក្ខណៈសម្រាប់ការរំខានដែលអាចកើតមាននៅមជ្ឈមណ្ឌលបោះឆ្នោត។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងមានបុគ្គលិកឃ្លាំងដែលមានមានបទពិសោធន៍ប្រចាំការ ដើម្បីចែកចាយសម្ភារនិងឧបករណ៍ជំនួសដែលចាំបាច់។ លើសពីនេះ បុគ្គលិកឃ្លាំងនឹងមានសមត្ថភាពដោះស្រាយបញ្ហាឧបករណ៍។ មជ្ឈមណ្ឌលបោះឆ្នោតទាំងអស់នឹងមានទូរសព្ទដៃដើម្បីភ្ជាប់បានរហ័សទៅនឹងការិយាល័យកណ្តាល នៅពេលចាំបាច់។ បុគ្គលិកមជ្ឈមណ្ឌលបោះឆ្នោតនឹងមានការបណ្តុះបណ្តាលអំពីទម្រង់ការជំនួស ដើម្បីឲ្យការបោះឆ្នោតនឹងបន្តក្នុងពេលមានការរំខានកើតឡើង។

DRAFT

# ជំពូក II - ទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោត

## ម៉ោងនៃទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោត

§4005(a)(1)(A)

ទីតាំងទម្លាក់សន្លឹកឆ្នោតនឹងត្រូវបើកចំនួន 28 ថ្ងៃ មុនពេលបោះឆ្នោត និងថ្ងៃបោះឆ្នោត។ ទីតាំងទម្លាក់សន្លឹកឆ្នោតនឹងត្រូវបើកនៅម៉ោងធ្វើការធម្មតានៅតាមទីតាំងរបស់ប្រអប់។ ទីតាំងទម្លាក់សន្លឹកឆ្នោត 24 ម៉ោង នឹងបិទនៅម៉ោង 8:00 យប់ នៅថ្ងៃបោះឆ្នោត។ ទីតាំងទម្លាក់សន្លឹកឆ្នោត និងម៉ោងគឺមានបង្ហាញនៅលើផែនទីអន្តរកម្មនៅលើវិបសាយរបស់នាយកដ្ឋាន www.stanvote.com ហើយមានដាក់បញ្ចូលនូវមគ្គុទេសក៍សម្រាប់ព័ត៌មានអ្នកបោះឆ្នោតនៅខោនធី Stanislaus ។

## ចំនួនប្រអប់សរុបនឹងត្រូវកំណត់នៅពេលក្រោយ។

§4005(a)(10)(I)(vi)(II)

ក្នុងអំឡុងការបោះឆ្នោតដកតំណែងអភិបាលរដ្ឋ California ឆ្នាំ 2021 ខោនធីត្រូវបានតម្រូវឱ្យបង្កើតប្រអប់ទម្លាក់សន្លឹកឆ្នោតចំនួន 18 ស្របតាមលក្ខខណ្ឌតម្រូវនៃ SB 450 និងចំនួនអ្នកបោះឆ្នោតរបស់ខោនធី។ ការិយាល័យចុះឈ្មោះបោះឆ្នោតបានឈានលើសពីលក្ខខណ្ឌតម្រូវនេះ ដោយបង្កើតប្រអប់ទម្លាក់សន្លឹកឆ្នោតចំនួន 25 ដែលអ្នកបោះឆ្នោតជាង 31,000 នាក់បានប្រគល់សន្លឹកឆ្នោតមកវិញ។ ដោយសារមានចំនួនអ្នកបោះឆ្នោតដែលបានចុះឈ្មោះបច្ចុប្បន្នមានចំនួន 282,482 នាក់គិតត្រឹមថ្ងៃទី 30 ខែសីហា ឆ្នាំ 2021 ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតរបស់ខោនធី Stanislaus ត្រូវបានតម្រូវឱ្យផ្តល់ប្រអប់ទម្លាក់សន្លឹកឆ្នោតយ៉ាងតិចចំនួន 19 កន្លែង។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនឹងបន្តឈានលើសពីលក្ខខណ្ឌតម្រូវសម្រាប់ការបោះឆ្នោតនាពេលខាងមុខ ដោយសារករណីបែបនេះទើបក្លាយជាវិធីសាស្ត្រដ៏ពេញនិយមមួយក្នុងការប្រគល់សន្លឹកឆ្នោតមកវិញក្នុងចំណោមអ្នកបោះឆ្នោត។ ទីតាំងទាំងនេះនឹងបើក 28 ថ្ងៃមុន និងនៅថ្ងៃបោះឆ្នោត។

ក្នុងអំឡុងការបោះឆ្នោតសកលឆ្នាំ 2020 និងការបោះឆ្នោតដកតំណែងអភិបាលរដ្ឋ California ឆ្នាំ 2021 ខោនធីបានបង្កើតប្រអប់ទម្លាក់សន្លឹកឆ្នោតសរុបចំនួន 2 កន្លែងដែលអាចប្រើបាន 24 ម៉ោង។ គោលដៅរបស់ការិយាល័យចុះឈ្មោះបោះឆ្នោតខោនធី Stanislaus គឺដើម្បីបង្កើនប្រអប់ទម្លាក់សន្លឹកឆ្នោតចំនួន 3 កន្លែងក្នុងរយៈពេល 24 ម៉ោងនៅឆ្នាំ 2022 សម្រាប់ការបោះឆ្នោតបឋមដោយផ្ទាល់នៅទូទាំងរដ្ឋ។

## ទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោត

§4005(a)(10)(I)(vi)(V)

ការិយាល័យចុះបញ្ជីអ្នកបោះឆ្នោតនៅខោនធី Stanislaus បានធ្វើការជាដៃគូជាមួយសហគមន៍ដើម្បីកំណត់ទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោតនៅទីកន្លែងដែលងាយស្គាល់ និងងាយចេញចូល។ ផែនទីនៃប្រអប់ទម្លាក់សន្លឹកឆ្នោតមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ D, ដែលនឹងត្រូវបានធ្វើបច្ចុប្បន្នភាព រាល់ពេលដែលទីតាំងត្រូវបានបញ្ជាក់បន្ថែមសម្រាប់ការបោះឆ្នោត។ បញ្ជីនោះនឹងត្រូវបានរួមបញ្ចូលនៅក្នុងសម្ភារបោះឆ្នោតដែលបានផ្តល់ទៅអ្នកបោះឆ្នោតដែលបានចុះឈ្មោះម្នាក់ៗ។

DRAFT

# ជំពូក III - ការកំណត់អត្តសញ្ញាណមជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោត

ប្រអប់ទម្លាក់សន្លឹកឆ្នោត និងទីតាំងមណ្ឌលបោះឆ្នោតជាច្រើនដែលធ្លាប់ប្រើពីមុននៅក្នុងការបោះឆ្នោតសកលឆ្នាំ 2020 និងការបោះឆ្នោតដកតំណែងអភិបាលរដ្ឋឆ្នាំ 2021 នឹងត្រូវប្រើប្រាស់ឡើងវិញព្រោះវាជាកន្លែងដែលមានភាពល្បីល្បាញ និងអាចចូលប្រើប្រាស់បាននៅក្នុងមជ្ឈមណ្ឌលប្រជាជនក្នុងខោនធី។ លើសពីនេះ នៅពេលដែលការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតខោនធី Stanislaus អនុម័តបញ្ជីរាយនាមសម្ភារ នាយកដ្ឋាននឹងពិចារណាលើកត្តាផ្សេងទៀត ជាអាទិ៍ រួមមាន ភាពជិតនៃមធ្យោបាយដឹកជញ្ជូនសាធារណ: តំបន់ដែលមានការបោះឆ្នោតតិចដោយការប្រើប្រាស់សំបុត្រ និងសហគមន៍ជនជាតិភាគតិចផ្នែកភាសា។

ផែនទីខាងក្រោមបង្ហាញពីការកើនឡើងគួរឱ្យកត់សម្គាល់នៃការបោះឆ្នោតតាមរយៈការប្រើប្រាស់សំបុត្រដោយអ្នកបោះឆ្នោតនៅក្នុងខោនធី Stanislaus។ ផែនទីចុងក្រោយ (ទំព័រ 19) បង្ហាញពីមជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោតដែលបានបង្កើតឡើងនៅក្នុងការបោះឆ្នោតដកតំណែងអភិបាលរដ្ឋ California ឆ្នាំ 2021 ទាក់ទងនឹងការបោះឆ្នោតតាមការប្រើប្រាស់សំបុត្រ។ មជ្ឈមណ្ឌលបោះឆ្នោត និងប្រអប់ទម្លាក់សន្លឹកឆ្នោតត្រូវបានកំណត់គោលដៅនៅក្នុងមជ្ឈមណ្ឌលប្រជាជន និងតំបន់ដែលមានក្រុមជនជាតិភាគតិចផ្នែកភាសា។

DRAFT


ខោនធី Stanislaus
ការបោះឆ្នោតសកលឆ្នាំ 2014 - អ្នកបោះឆ្នោតដែលបានចុះឈ្មោះ
ដែលបានបោះឆ្នោតតាមសំបុត្រ
Oakdale
Riverbank
Salida
Modesto
Waterford
Ceres
Hughson
Keyes
Denair
Turlock
Patterson
Newman
ភាគរយនៃអ្នកបោះឆ្នោតដែលបានចុះ
ឈ្មោះដែលបានបោះឆ្នោតតាមសំបុត្រ
0 - 20%
20 - 40%
40 - 60%
60 - 80%
80 - 100%
អ្នកបោះឆ្នោតដែលបានចុះឈ្មោះ
តិចជាង 10 នាក់។
N
0
5
10
20 Miles


ខោនធី Stanislaus
ការបោះឆ្នោតសកលឆ្នាំ 2016 - អ្នកបោះឆ្នោតដែលបានចុះឈ្មោះ
ដែលបានបោះឆ្នោតតាមសំបុត្រ
Oakdale
Riverbank
Salida
Modesto
Waterford
Ceres
Hughson
Keyes
Denair
Turlock
Patterson
Newman
ភាគរយនៃអ្នកបោះឆ្នោតដែលបានចុះ
ឈ្មោះដែលបានបោះឆ្នោតតាមសំបុត្រ
0 - 20%
20 - 40%
40 - 60%
60 - 80%
80 - 100%
អ្នកបោះឆ្នោតដែលបានចុះឈ្មោះ
តិចជាង 10 នាក់។
N
0
5
10
20 Miles


ខោនធី Stanislaus
ការបោះឆ្នោតសកលឆ្នាំ 2018 - អ្នកបោះឆ្នោតដែលបានចុះឈ្មោះ
ដែលបានបោះឆ្នោតតាមសំបុត្រ
Oakdale
Riverbank
Salida
Modesto
Waterford
Ceres
Hughson
Keyes
Denair
Turlock
Patterson
Newman
ភាគរយនៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះដែលបានបោះឆ្នោតតាមសំបុត្រ
0 - 20%
20 - 40%
40 - 60%
60 - 80%
80 - 100%
អ្នកបោះឆ្នោតដែលបានចុះឈ្មោះតិចជាង 10 នាក់។
N
0
5
10
20 Miles


ខោនធី Stanislaus
ការបោះឆ្នោតសកលឆ្នាំ 2020 - អ្នកបោះឆ្នោតដែលបានចុះឈ្មោះ
ដែលបានបោះឆ្នោតតាមសំបុត្រ
Oakdale
Riverbank
Salida
Modesto
Waterford
Ceres
Hughson
Keyes
Denair
Turlock
Patterson
Newman
ភាគរយនៃអ្នកបោះឆ្នោតដែលបានចុះ
ឈ្មោះដែលបានបោះឆ្នោតតាមសំបុត្រ
0 - 20%
20 - 40%
40 - 60%
60 - 80%
80 - 100%
អ្នកបោះឆ្នោតដែលបានចុះ
ឈ្មោះតិចជាង 10 នាក់។
មជ្ឈមណ្ឌលបោះឆ្នោត
ប្រអប់ទម្លាក់សន្លឹកឆ្នោត
N
0 5 10 20 Miles

# ជំពូក IV - ការចំណាយ និងការសន្សំប្រាក់ដែលបានប៉ាន់ស្មានសម្រាប់រយៈពេលខ្លី និងរយៈពេលវែង

## ការចំណាយ និងការសន្សំប្រាក់ដែលបានប៉ាន់ស្មាននៅក្រោមផែនការនេះ

§4005(A)(10)(I)(v), §4005(g)(2)

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus បានកំណត់ថា ការចំណាយនឹងច្រើនជាងការសន្សំប្រាក់នៅពេលអនុវត្ត VCA ដំបូង។ ទោះយ៉ាងណា ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus ប៉ាន់ស្មានថា នៅពេលខាងមុខ ការរៀបចំការបោះឆ្នោតស្របតាម VCA នឹងជំរុញឲ្យមានការសន្សំប្រាក់ ដោយផ្អែកលើភស្តុតាងមកពី Colorado ដែលបានអនុវត្តម៉ូដែលបោះឆ្នោតស្រដៀងគ្នា ហើយខោនធីផ្សេងទៀតនៅ California ដែលបានប្រើម៉ូដែល VCA តាំងពីឆ្នាំ 2018។ យោងតាមរបាយការណ៍ដែលបានបោះពុម្ពផ្សាយដោយ The EW Charitable Trusts ការចំណាយលើការបោះឆ្នោតបានថយចុះ 40% ជាមធ្យម ក្រោយពីការអនុវត្តក្រមច្បាប់ស្តីពីការបោះឆ្នោតដែលមានសិទ្ធិចូលប្រើប្រាស់ និងលក្ខណៈទំនើបរបស់រដ្ឋ Colorado ឆ្នាំ 2013។ ខោនធី Stanislaus បានចំណាយរយៈពេលខ្លីខ្លះ ដូចជា ការទិញសន្លឹកឆ្នោត ដោយការទិញម៉ាស៊ីនព្រីនគុណភាពល្អសម្រាប់មជ្ឈមណ្ឌលបោះឆ្នោតទាំងអស់ ដែលនឹងអនុញ្ញាតឲ្យបុគ្គលិកអាចព្រីនគ្រប់ប្រភេទសន្លឹកឆ្នោតនៅក្នុងខោនធីសម្រាប់ការបោះឆ្នោត។ ការចំណាយទាំងនេះធ្វើឡើងនៅឆ្នាំ 2020 ដើម្បីជួយឲ្យខោនធី Stanislaus ធ្វើការបោះឆ្នោតប្រធានាធិបតីកាលពីខែវិច្ឆិកា ឆ្នាំ 2020 បានយ៉ាងជោគជ័យក្នុងពេលមានជំងឺរាតត្បាតដោយវីរុសកូរ៉ូណា។ ការចំណាយរយៈពេលខ្លីរបស់ខោនធី Stanislaus នឹងកើតឡើងនៅក្នុងការបោះឆ្នោត VCA នាពេលខាងមុខ ជាអាទិ៍ រួមមាន ការបណ្តុះបណ្តាលទ្រង់ទ្រាយធំសម្រាប់បុគ្គលិក ការទិញប្រអប់ទម្លាក់សន្លឹកឆ្នោត ការជួលទីកន្លែង និងការផ្សព្វផ្សាយដល់សហគមន៍ និងការចំណាយលើការផ្សព្វផ្សាយ សម្រាប់ការផ្ញើសំបុត្រផ្ទាល់ចាំបាច់។ ការសន្សំប្រាក់រយៈពេលវែងដែលបានរំពឹងទុករួមមាន ការថយចុះការចំណាយសម្រាប់ឧបករណ៍ ដូចជាការទិញឧបករណ៍ថ្មី និងការថែទាំឧបករណ៍ ការព្រីនសន្លឹកឆ្នោត និងកម្លាំងពលកម្មដើម្បីអនុលោមតាមលក្ខខណ្ឌតម្រូវធំៗបន្ថែមសម្រាប់សហគមន៍ និងការចូលរួមដោយអ្នកបោះឆ្នោត។ សូមមើលឧបសម្ព័ន្ធ E សម្រាប់ឧទាហរណ៍នៃថវិកា និងការចំណាយដែលបានរំពឹងទុក និងការសន្សំប្រាក់ពាក់ព័ន្ធនឹងក្រឹត្យជម្រើសរបស់អ្នកបោះឆ្នោត។

# ជំពូក V -ការអប់រំ និងការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត – ទូទៅ

## ទិដ្ឋភាពទូទៅ

ក្រឹត្យជម្រើសរបស់អ្នកបោះឆ្នោតតម្រូវឲ្យខោនធីបង្កើតផែនការអប់រំ និងការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត ដែលជូនដំណឹងដល់អ្នកបោះឆ្នោត និងពលរដ្ឋដែលមានលក្ខណសម្បត្តិ អំពីគ្រប់ទិដ្ឋភាពនៃ VCA រួមមានទាំងមជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោតដែលបានអនុញ្ញាត ការបោះឆ្នោតតាមសំបុត្រ និងព័ត៌មានជាក់លាក់ទៅនឹងអ្នកបោះឆ្នោតដែលមានពិការភាព និងអ្នកបោះឆ្នោតដែលមិននិយាយភាសាអង់គ្លេស។ ការប្រជុំសាធារណៈនឹងធ្វើឡើងជាមួយអង្គការសហគមន៍ និងបុគ្គលដែលធ្វើការតស៊ូមតិក្នុងនាម ឬផ្តល់សេវាកម្មដល់ក្រុមទាំងនេះ។

ការជួយសម្រួលសមហេតុផលៈ ស្របតាមច្បាប់ជនពិការអាមេរិក ប្រសិនបើអ្នកត្រូវការជំនួយពិសេសនៅក្នុងការប្រជុំនេះ សូមទាក់ទងមកការិយាល័យបោះឆ្នោត។ ការជូនដំណឹង 72ម៉ោងមុននឹងការប្រជុំនឹងជួយដល់ខោនធីក្នុងការរៀបចំសមហេតុផលដើម្បីធានាលទ្ធភាពចេញចូលទៅក្នុងការប្រជុំទាំងនេះ។

មន្ត្រីចុះឈ្មោះអ្នកបោះឆ្នោតឈ្មោះ Donna Linder និងអ្នកដឹកនាំនៅក្នុងផ្នែកបោះឆ្នោតប្រចាំខោនធី Stanislaus កំពុងធ្វើការជាមួយគណៈកម្មការប្រឹក្សាយោបល់លទ្ធភាពចូលទៅបោះឆ្នោត និងគណៈកម្មការប្រឹក្សាយោបល់លទ្ធភាពប្រើប្រាស់ការបោះឆ្នោត (Voting Accessibility Advisory Committee, VAAC) និងគណៈកម្មការប្រឹក្សាយោបល់លទ្ធភាពប្រើប្រាស់ភាសា (Language Accessibility Advisory Committee, LAAC) ដើម្បីបង្កើតផែនការអប់រំ និងការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត។

## ប្រព័ន្ធផ្សព្វផ្សាយ និងការប្រកាសអំពីសេវាកម្មសាធារណៈ

*§4005(a)(10)(I)(i)(II), §4005(a)(10)(I)(i)(VIII)*

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗតាមទម្រង់ដែលអាចប្រើប្រាស់បាន ដើម្បីអប់រំដល់សាធារណៈជននៅក្នុងខោនធី Stanislaus ដើម្បីផ្សព្វផ្សាយអំពីវត្តមាន និងលទ្ធភាពចូលប្រើប្រាស់សន្លឹកឆ្នោតតាមសំបុត្រ និងរបៀបស្នើសុំសន្លឹកឆ្នោត។ ប្រព័ន្ធផ្សព្វផ្សាយ ជាអាទិ៍រួមមានៈ

- i) កាសែត, Modesto Bee, Turlock Journal, Latino Times, Ceres Courier, Oakdale Leader, Patterson Irrigator, Mattos News
- ii) វិទ្យុ (KBDG-FM 90.9 MHz, Radio Lazer, Punjabi Radio USA)
- iii) ប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គម វិបសាយរបស់នាយកដ្ឋាន Facebook Stanislaus, Turlock City News បណ្តាញសង្គមរបស់ស្មៀនក្រុងផ្សេងទៀត
- iv) ការផ្សព្វផ្សាយដល់ក្រុម ដូចជាអង្គការសហគមន៍ អង្គការជួយជនពិការ មន្ត្រីជាប់ឆ្នោតស្រុកពិសេស មន្ត្រីព័ត៌មានសាធារណៈ ក្រុង។ បញ្ជីក្រុម ឬអង្គការ ឬទីភ្នាក់ងារដែលការិយាល័យបោះឆ្នោតទាក់ទង អាចរកបាននៅលើវិបសាយ stanvote.com នៅក្នុងផ្នែកសេចក្តីជូនដំណឹងសាធារណៈ ហើយនឹងត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ។
- v) នាយកដ្ឋានខោនធី
- vi) ការប្រកាសអំពីសេវាកម្មសាធារណៈ

ការខិតខំប្រែងប្រែងធំៗសម្រាប់អប់រំដល់មនុស្សដែលអាចបោះឆ្នោតបាន នឹងត្រូវបានធ្វើឡើងនៅតាមប្រព័ន្ធផ្សព្វផ្សាយនៅខាងលើ។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងបន្តគាំទ្រដល់សាធារណៈជន និងនឹងកំណត់ពេលវេលាប្រាស្រ័យទាក់ទង នៅពេលខិតជិតដល់កាលបរិច្ឆេទបោះឆ្នោតសំខាន់ៗ។

## ការមានវត្តមាននៃសហគមន៍

§4005(a)(10)(I)(i)(III)

ការរៀបចំ និងការអនុម័ត EAP ដែលបានស្នើឡើងគឺជាជំហានដំបូងក្នុងការធ្វើឲ្យមានការចូលរួមពីអង្គការសហគមន៍ សហការី សាលារៀន និងអង្គភាពផ្សេងទៀត ដើម្បីលើកកម្ពស់ការយល់ដឹងនៃម៉ូដែលបោះឆ្នោតថ្មី។ ខណៈយើងកំពុងឆ្ពោះទៅមុខ យើងនឹងបន្តស្វែងរកការចូលរួមមតិយោបល់ពីសាធារណៈជនសម្រាប់ការកែប្រែនាពេលអនាគតនៃ EAP។ កិច្ចខិតខំប្រឹងប្រែងកាន់តែច្រើននឹងត្រូវបានធ្វើឡើងដើម្បីផ្សព្វផ្សាយវិបសាយរបស់នាយកដ្ឋានបោះឆ្នោត និងផ្តល់ជំនួយតាមទូរសព្ទ ដើម្បីអប់រំដល់អ្នកបោះឆ្នោត អំពីរបៀបទទួលបានជំនួយផ្នែកភាសា និង/ឬជនពិការ។

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងកំណត់ពេលវេលាធ្វើសិក្ខាសាលាអប់រំអ្នកបោះឆ្នោត ដើម្បីបង្កើនការយល់ដឹងអំពីលទ្ធភាពប្រើប្រាស់ និងការចូលរួមរបស់អ្នកបោះឆ្នោតពិការដែលមានសិទ្ធិបោះឆ្នោត។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus ក៏នឹងផ្តល់ការតំណាងទាក់ទងនឹងក្រឹត្យជម្រើសរបស់អ្នកបោះឆ្នោត នៅតាមបណ្តាព្រឹត្តិការណ៍នានានៅក្នុងខោនធី Stanislaus ។ គោលដៅរបស់ការិយាល័យចុះឈ្មោះបោះឆ្នោតគឺ បង្កើតការសហការរឹងមាំរវាងនាយកដ្ឋានរបស់យើង និងសមាជិក LAAC និង VAAC ដើម្បីរកឃើញឱកាសអប់រំបានកាន់តែប្រសើរដល់អ្នកបោះឆ្នោតអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេ, ផ្តល់ការបង្ហាញអំពីឧបករណ៍បោះឆ្នោត និងពន្យល់អំពីជម្រើសរបស់ពួកគេនៅក្រោមក្រឹត្យជម្រើសរបស់អ្នកបោះឆ្នោត។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងខិតខំផ្សព្វផ្សាយនៅតាមតំបន់នីមួយៗនៅក្នុងខោនធី។ ការអប់រំអំពីក្រឹត្យជម្រើសរបស់អ្នកបោះឆ្នោត នឹងត្រូវបានផ្តល់ជូនដល់ក្រុមសហគមន៍ជាច្រើន រួមទាំង៖

1) VAAC និង LAAC របស់នាយកដ្ឋាន
    a. ការប្រជុំរួមមានការបង្ហាញអំពីប្រព័ន្ធបោះឆ្នោត និងបច្ចុប្បន្នភាពផ្នែកព័ត៌មាន
    b. សម្ភារអប់រំអាចត្រូវបានបង្កើតឡើងដើម្បីចែកចាយដល់សមគមន៍របស់ពួកគេ

2) ការបង្ហាញដល់ទស្សនិកជនផ្សេងៗ៖
    a. ក្រុមប្រឹក្សាភិបាលនៃអ្នកដឹកនាំនៃខោនធី
    b. សាលាក្រុងរបស់មន្ត្រីជាប់ឆ្នោត
    c. គណៈកម្មការមជ្ឈឹមខោនធី និងគណៈកម្មការនយោបាយ
    d. ស្មៀនក្រុង
    e. អង្គការផ្តល់សេវាកម្ម (ដូចជា Rotary, Kiwanis)

បញ្ជីនៃព្រឹត្តិការណ៍កាលពីអតីតកាលដែលព័ត៌មានស្តីពីក្រឹត្យជម្រើសរបស់អ្នកបោះឆ្នោតនឹងត្រូវបានចែករំលែក អាចរកឃើញនៅក្នុងឧបសម្ព័ន្ធ A។ សម្រាប់បញ្ជីពេញលេញនៃព្រឹត្តិការណ៍ សូមចូលមើល "សេចក្តីជូនដំណឹងសាធារណៈ" នៅលើ www.stanvote.com។

យើងមានផែនការពង្រីកព្រឹត្តិការណ៍សហគមន៍ និងបញ្ជីដៃគូសហគមន៍នៅក្នុងដំណើរការធ្វើបច្ចុប្បន្នភាព EAP។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងសង្កត់ធ្ងន់លើវត្តមាន និងលទ្ធភាពប្រើប្រាស់សន្លឹកឆ្នោតបោះតាមសំបុត្រ។ ការិយាល័យនឹងមានការប្រជុំជាមួយសាធារណជន ហើយនឹងបន្តមានការប្រជុំជាមួយសមាជិកសហគមន៍។ នាយកដ្ឋានក៏នឹងផ្តល់សម្ភារសម្រាប់ ឬចូលរួមនៅក្នុងព្រឹត្តិការណ៍ក្នុងមូលដ្ឋាន ដែលត្រូវបានណែនាំដោយបុគ្គលិក និងសមាជិកសហគមន៍របស់យើង។

DRAFT

## ការទាក់ទងទៅអ្នកបោះឆ្នោតដោយផ្ទាល់

§4005(a)(10)(I)(i)(X)

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងធ្វើការទាក់ទងផ្ទាល់ពីរដងទៅអ្នកបោះឆ្នោតតាមសំបុត្រ ក្នុងគោលបំណងជូនដំណឹងដល់អ្នកបោះឆ្នោតអំពីការបោះឆ្នោតនៅពេលខាងមុខ និងផ្សព្វផ្សាយអំពីជំនួយអ្នកបោះឆ្នោតតាមបណ្ដាញទូរសព្ទទាន់ហេតុការណ៍ដោយឥតគិតថ្លៃ។ ការផ្ញើសំបុត្រផ្ទាល់ទាំងនេះគឺជាការបន្ថែមពីលើការទាក់ទងចាំបាច់ផ្សេងទៀត ដូចជា មគ្គុទេសក៍សម្រាប់ព័ត៌មានអ្នកបោះឆ្នោត និងការផ្ដល់ការបោះឆ្នោតតាមសន្លឹកឆ្នោតបោះតាមសំបុត្រ។ ការផ្ញើសំបុត្រដំបូងទៅកាន់អ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅក្នុងខោនធី Stanislaus នឹងជូនដំណឹងដល់អ្នកបោះឆ្នោតថា ការបោះឆ្នោតតាមសំបុត្រនឹងត្រូវបានផ្ញើទៅអ្នកបោះឆ្នោតដែលបានចុះឈ្មោះសកម្មទាំងអស់ ទោះបីគេចង់បោះឆ្នោតតាមសំបុត្រឬអត់ក៏ដោយ។ ការផ្ញើសំបុត្រលើកទីពីរនឹងត្រូវធ្វើឡើងក្រោយពេលសន្លឹកឆ្នោតត្រូវបានផ្ញើចេញ ដើម្បីជូនដំណឹងដល់អ្នកបោះឆ្នោតអំពីជម្រើសនៃការបោះឆ្នោតនៅមជ្ឈមណ្ឌលបោះឆ្នោត ប្រសិនបើពួកគេចង់បោះឆ្នោតផ្ទាល់ខ្លួន និងជម្រើសសម្រាប់ការប្រគល់សន្លឹកឆ្នោតតាមសំបុត្រ។

## វិបសាយរបស់ការិយាល័យចុះបញ្ជីអ្នកបោះឆ្នោតនៅខោនធី Stanislaus

§4005(a)(5)(6)(ii)(iii)

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងមានផ្តល់ព័ត៌មានតាមវិបសាយរបស់ខ្លួន ដើម្បីជួយដល់អ្នកបោះឆ្នោតដោយប្រាប់ព័ត៌មានអំពីរបៀបចូលប្រើពីចម្ងាយនូវសន្លឹកឆ្នោតបោះតាមសំបុត្រ (remote accessible vote by mail, RAVBM) ព្រមទាំងធនធានជំនួយតាមភាសា។ ក្នុងពេលបោះឆ្នោត ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតក្នុងខោនធី Stanislaus, www.stanvote.com, នឹងមានផែនទីអន្តរកម្ម និងមានបញ្ជីបង្ហាញអំពីសន្លឹកឆ្នោតដែលបានទម្លាក់ និងទីតាំងនៃមជ្ឈមណ្ឌលបោះឆ្នោត ព្រមទាំងម៉ោងប្រតិបត្តិការ។

## ការប្រើប្រាស់ធនធានដើម្បីធានាថា អ្នកបោះឆ្នោតត្រូវបានជូនដំណឹង

§4005(a)(10)(I)(i)(VII)

ការិយាល័យចុះបញ្ជីអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងចំណាយធនធានចាំបាច់ទៅលើការអប់រំអ្នកបោះឆ្នោត និងការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត ដើម្បីធានាថា អ្នកបោះឆ្នោតត្រូវបានជូនដំណឹងពេញលេញអំពីការបោះឆ្នោតដែលបានធ្វើឡើង ស្របទៅតាមក្រឹត្យជម្រើសរបស់អ្នកបោះឆ្នោត។ ការប៉ាន់ប្រមាណការចំណាយលើការបោះឆ្នោត រួមទាំងការចំណាយលើការផ្សព្វផ្សាយត្រូវបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ E។

DRAFT

## ជំពូក VI-ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី STANISLAUS - ការអប់រំ និងការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត –អ្នកបោះឆ្នោតដែលមានតម្រូវការក្នុងការចេញចូល

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតរបស់ខោនធី Stanislaus បានបង្កើតគណៈកម្មាធិការប្រឹក្សាស្តីពីលទ្ធភាពចូលប្រើប្រាស់របស់អ្នកបោះឆ្នោត ហើយបានបើកកិច្ចប្រជុំគណៈកម្មាធិការជាលើកដំបូងរបស់ខ្លួននៅថ្ងៃទី 21 ខែមិថុនា ឆ្នាំ 2021។ ត្រូវបានបង្កើតឡើងដើម្បីបង្កើតរបៀបអប់រំ និងផ្សព្វផ្សាយដល់សហគមន៍ជនពិការនៅក្នុងខោនធី Stanislaus ពាក់ព័ន្ធនឹង VCA។ សមាជិកគណៈកម្មការកំពុងត្រូវបានជ្រើសរើសដោយផ្អែកលើការចូលរួមរបស់ពួកគេនៅក្នុងសហគមន៍ដែលមានតម្រូវការក្នុងការចេញចូល។

គោលបំណងនៃគណៈកម្មការប្រឹក្សាយោបល់លទ្ធភាពចេញចូលរបស់អ្នកបោះឆ្នោត (VAAC) គឺដើម្បីផ្តល់ដំបូន្មាន និងជួយដល់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus ក្នុងការកែលម្អដំណើរការបោះឆ្នោតសម្រាប់អ្នកបោះឆ្នោតដែលជាជនពិការ។

- សមាជិក VAAC នឹងជួយឲ្យខោនធីបន្តរកឃើញវិធីកាន់តែមានប្រសិទ្ធភាពក្នុងការផ្តល់ការអប់រំអំពីអ្នកបោះឆ្នោត និងការជួយដល់អ្នកបោះឆ្នោតដែលមានតម្រូវការក្នុងការចេញចូល។
- ផ្តល់សាធារណជននូវវេទិកាដើម្បីផ្តល់អនុសាសន៍អំពីរបៀបកែលម្អលទ្ធភាពទទួលបានសម្ភារបោះឆ្នោត។
- សមាជិក VAAC នឹងផ្តល់អនុសាសន៍អំពីរបៀបកែលម្អលទ្ធភាពសម្រាប់អ្នកបោះឆ្នោតទាំងអស់ដើម្បីបោះឆ្នោតដោយឯករាជ្យ និងដោយឯកជន។
- សមាជិក VAAC អាចផ្តល់អនុសាសន៍អំពីការកែលម្អទម្រង់ការដែលនឹងត្រូវពិចារណាសម្រាប់ការអនុម័តដោយការិយាល័យចុះបញ្ជីអ្នកបោះឆ្នោត។

សាធារណៈជនដែលមានចំណាប់អារម្មណ៍ និងមានការប្តេជ្ញាចិត្តត្រូវបានលើកទឹកចិត្តឱ្យចូលរួមជាមួយ VAAC។ សម្រាប់ព័ត៌មានអំពីរបៀបដាក់ពាក្យ សូមចូលទៅកាន់គេហទំព័រ www.stanvote.com។

### ការអប់រំសហគមន៍ជនពិការ– សិក្ខាសាលាអប់រំអ្នកបោះឆ្នោត

§4005(a)(10)(I)(i)(VI)(ib)

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតខោនធី Stanislaus នឹងធ្វើសិក្ខាសាលាអប់រំអ្នកបោះឆ្នោតដើម្បីបង្កើនលទ្ធភាពប្រើប្រាស់ និងការចូលរួមរបស់អ្នកបោះឆ្នោតពិការដែលមានសិទ្ធិបោះឆ្នោត។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus ក៏នឹងផ្តល់ការបង្ហាញអំពីក្រឹត្យជម្រើសរបស់អ្នកបោះឆ្នោតនៅតាមបណ្តាព្រឹត្តិការណ៍នានា។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus មានគោលដៅសម្របសម្រួលជាមួយដៃគូសហគមន៍ និង VAAC ដើម្បីកំណត់អត្តសញ្ញាណឱកាសដើម្បីអប់រំដល់អ្នកបោះឆ្នោតរបស់យើងអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេ ផ្តល់ការបង្ហាញអំពីឧបករណ៍បោះឆ្នោត និងពន្យល់អំពីរបៀបស្នើសុំ ទទួល និងដាក់សន្លឹកឆ្នោតដែលអាចបោះបាន។ សិក្ខាសាលាអប់រំបន្ថែមទៀតនឹងត្រូវធ្វើឡើងមុនការបោះឆ្នោតដែលបានកំណត់ពេលដែលអនុញ្ញាតឱ្យអ្នកបោះឆ្នោតទទួលបានព័ត៌មានជាមុននៅពេលពួកគេគិតអំពីការបោះឆ្នោត។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងខិតខំដើម្បីទៅដល់គ្រប់តំបន់នៅក្នុងខោនធី។ អ្នកបោះឆ្នោតនឹងមានឱកាសជាច្រើនដើម្បីស្វែងយល់អំពីម៉ូដែលរបស់មជ្ឈមណ្ឌលបោះឆ្នោត និងជម្រើសបោះឆ្នោតរបស់ពួកគេ ជាអាទិ៍រួមមានដូចជា៖

DRAFT

1) VAAC និង LAAC របស់នាយកដ្ឋាន
    a. ការប្រជុំរួមមានការបង្ហាញអំពីប្រព័ន្ធបោះឆ្នោត និងបច្ចុប្បន្នភាពផ្នែកព័ត៌មាន
    b. បង្កើតសម្ភារអប់រំជាមួយ VAAC និង LAAC ដើម្បីចែកចាយដល់សមគមន៍របស់ពួកគេ

2) ការបង្ហាញដល់ទស្សនិកជនផ្សេងៗ៖
    a. ក្រុមប្រឹក្សាភិបាលនៃអ្នកដឹកនាំនៃខោនធី
    b. សាលាក្រុងរបស់មន្ត្រីជាប់ឆ្នោត
    c. គណៈកម្មការមជ្ឈឹមខោនធី និងគណៈកម្មការនយោបាយ
    d. ស្មៀនក្រុង
    e. អង្គការផ្តល់សេវាកម្ម (ដូចជា Rotary, Kiwanis)

## សម្ភារបោះឆ្នោត និងសន្លឹកឆ្នោតសម្រាប់ជនពិការ និងវិបសាយសម្រាប់ជនពិការ

§4005(a)(10)(I)(i)(IV)

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងធ្វើការជាមួយបុគ្គលិកផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យារបស់ខោនធី Stanislaus ដើម្បីធានាថា រាល់ព័ត៌មានបោះឆ្នោតគឺអាចមើលបានជាទម្រង់អត្ថបទ នៅលើវិបសាយសម្រាប់ជនពិការ www.stanvote.com។ ព័ត៌មានអាចរួមមានដូចជាបញ្ជីនៃទីតាំងទម្លាក់សន្លឹកឆ្នោត និងមជ្ឈមណ្ឌលបោះឆ្នោត ជាមួយនឹងកាលបរិច្ឆេទ និងម៉ោងដែលពួកគេបើកធ្វើការ ព្រមទាំងសេវាកម្មដែលមាននៅមជ្ឈមណ្ឌលបោះឆ្នោត។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus ក៏កំពុងមានផែនការធ្វើវិបសាយដើម្បីអប់រំដល់សាធារណជនអំពីឧបករណ៍បោះឆ្នោតសម្រាប់ជនពិការដែលអាចប្រើប្រាស់បាន។

## សេវាកម្មសម្រាប់ជនពិការដែលអាចប្រើប្រាស់បាននៅមជ្ឈមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សន្លឹកឆ្នោត

§4005(a)(10)(I)(vi)(X)

មជ្ឈមណ្ឌលបោះឆ្នោតនីមួយៗនឹងមានចំណតសម្រាប់ជនពិការ។ មជ្ឈមណ្ឌលបោះឆ្នោតនឹងត្រូវបានស្ទង់មតិដោយបុគ្គលិក ដើម្បីធានាថា ទីតាំងនីមួយៗមានឧបករណ៍ និងសម្ភារប្រើប្រាស់តាមការកំណត់របស់ ច្បាប់ស្តីពីជនជាតិអាមេរិកដែលមានពិការភាព (Americans with Disabilities Act, ADA)។

មជ្ឈមណ្ឌលបោះឆ្នោតទាំងអស់នឹងត្រូវបានបំពាក់ដោយឧបករណ៍គូសសន្លឹកឆ្នោតសម្រាប់ជនពិការយ៉ាងហោចណាស់បីគ្រឿង (HART TouchWriter) និងមានសន្លឹកឆ្នោតក្រដាស ប្រសិនបើចង់ប្រើ។ ឧបករណ៍គូសសន្លឹកឆ្នោតសម្រាប់ជនពិការបង្ហាញការណែនាំអំពីការបោះឆ្នោត និងសន្លឹកឆ្នោតជាប្រភេទអត្ថបទអក្សរធំ អាចប៉ះ និងទម្រង់ជាសំឡេង។ ឧបករណ៍នេះក៏អនុញ្ញាតឱ្យប្រើឧបករណ៍ជំនួយផ្សេងទៀតផងដែរ (ឧ. ឧបករណ៍ផ្លុំខ្យល់ផ្តល់សញ្ញា បិទបើកប៉ះជាដើម)

បន្ទាប់ពីទទួលបានមតិកែលម្អពីសមាជិក VAAC ខោនធីបានទិញកណ្តឹងចុចហៅថ្មីៗសម្រាប់មជ្ឈមណ្ឌលបោះឆ្នោតនីមួយៗ។ កណ្តឹងចុចហៅត្រូវបានដាក់នៅផ្នែកចំហៀងអ្នកបើកបរនៃកន្លែងចតរថយន្តដែលអាចចេញចូលបាន។ បែបនេះអនុញ្ញាតឱ្យអ្នកបោះឆ្នោតដែលមិនអាចចេញពីយានជំនិះរបស់ពួកគេ ទទួលបានសេវាកម្មនានារួមទាំងការទម្លាក់សន្លឹកឆ្នោត VBM ការចុះឈ្មោះបោះឆ្នោត ឬការធ្វើបច្ចុប្បន្នភាពការចុះឈ្មោះអ្នកបោះឆ្នោតជាដើម។ បើអាច មជ្ឈមណ្ឌលបោះឆ្នោតមួយចំនួនក៏ផ្តល់កន្លែងទម្លាក់សន្លឹកឆ្នោតនៅខាងមុខផងដែរ ដើម្បីឱ្យអ្នកបោះឆ្នោតអាចទម្លាក់ VBM ដោយមិនចាំបាច់ចេញពីយានជំនិះរបស់ពួកគេ។

ស្មៀនរៀបចំការបោះឆ្នោត និងអ្នកស្ម័គ្រចិត្តនឹងត្រូវបានបណ្ដុះបណ្ដាលដើម្បីជួយអ្នកបោះឆ្នោ
តតាមវិធីល្អបំផុតដែលអាចធ្វើទៅបាន ហើយការិយាល័យចុះឈ្មោះបោះឆ្នោតរបស់ខោនធី Stanislaus
មានបទពិសោធន៍ក្នុងការប្រើប្រាស់ឧបករណ៍នេះ។ ស្មៀនរៀបចំការបោះឆ្នោត និងអ្នកស្ម័គ្រចិត្តត្រូវចូល
រួមវគ្គបណ្ដុះបណ្ដាលមុនពេលបម្រើនៅមជ្ឈមណ្ឌលបោះឆ្នោត។ វគ្គបណ្ដុះបណ្ដាលនេះរួមមានការយល់ឃើ
ញពីភាពពិការ និងការជួយអ្នកបោះឆ្នោតជាមួយនឹងសេវាកម្មដែលបានរៀបរាប់។

ទីតាំងទម្លាក់សន្លឹកឆ្នោតខាងក្រៅនិងខាងក្នុងទាំងអស់ នឹងអាចចូលបាន និងនៅជិតផ្លូវធ្វើដំណើរសា
ធារណៈតាមដែលអាចធ្វើបាន។ ទីតាំងទម្លាក់សន្លឹកឆ្នោត 24 ម៉ោងនៅការិយាល័យចុះឈ្មោះអ្នកបោះ
ឆ្នោតនៅខោនធី Stanislaus (1021 “I” Street) គឺអាចចូលប្រើបាន និងនៅលើផ្លូវធ្វើដំណើរសាធារណៈ។

## ការស្នើសុំសន្លឹកឆ្នោតបោះតាមសំបុត្រសម្រាប់ជនពិការ

§4005(a)(8)(B)(iii)

អ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់នឹងទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រជាភាសាអង់គ្លេស
និងអេស្ប៉ាញ។ អ្នកបោះឆ្នោតដែលចង់បានសន្លឹកឆ្នោតជនពិការសម្រាប់បោះតាមសំបុត្រអាចប្រើប្រា
ស់កម្មវិធីបោះឆ្នោតពីចម្ងាយសម្រាប់ជនពិការតាមសំបុត្រ (RAVBM)។ RAVBM អនុញ្ញាតឲ្យអ្នកបោះឆ្នោ
តប្រើប្រាស់សុហ្វវែរពិការភាពរបស់ពួកគេផ្ទាល់ខ្លួន ដើម្បីមើលមគ្គុទេសក៍សម្រាប់ព័ត៌មានអ្នកបោះ
ឆ្នោតប្រចាំខោនធីដែលអាចចូលប្រើប្រាស់បាន និងគូសសន្លឹកឆ្នោតជនពិការនៅផ្ទះ។ ការប្រើប្រាស់
RAVBM តម្រូវឱ្យមានម៉ាស៊ីនបោះពុម្ព ដូច្នេះសន្លឹកឆ្នោតដែលបានគូសធីកអាចបោះពុម្ពចេញបាន
បន្ទាប់មកដាក់បញ្ជូនជាទម្រង់ក្រដាស។ អ្នកបោះឆ្នោតអាចប្រគល់ស្រោមសំបុត្រមកវិញដោយប្រើ
ប្រាស់ស្រោមសំបុត្រដែលមាននៅក្នុងកញ្ចប់ទាញយក ឬប្រើស្រោមសំបុត្រប្រគល់ត្រឡប់មកវិញដោយ
ផ្ញើរួមជាមួយការបោះឆ្នោតតាមសន្លឹកឆ្នោតផ្ញើតាមសំបុត្រ។ អ្នកបោះឆ្នោតអាចជ្រើសរើសប្រគល់ស្រោ
មសំបុត្រសន្លឹកឆ្នោតដែលបានចុះហត្ថលេខាតាមសំបុត្រ នៅតាមប្រអប់ទម្លាក់សន្លឹកឆ្នោត ឬនៅម
ជ្ឈមណ្ឌលបោះឆ្នោត។ ព័ត៌មាន RAVBM ត្រូវបានផ្ដល់នៅក្នុងមគ្គុទេសក៍សម្រាប់ព័ត៌មានអ្នកបោះ
ឆ្នោតប្រចាំខោនធី និងនៅលើវិបសាយនាយកដ្ឋានបោះឆ្នោត www.stanvote.com។ ការិយាល័យចុះ
ឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងប្រើប្រាស់ប្រព័ន្ធលទ្ធិប្រជាធិបតេយ្យផ្សាយផ្ទាល់
(Democracy Live) ដើម្បីចែកចាយសន្លឹកឆ្នោតជនពិការបោះតាមសំបុត្រ។ អ្នកបោះឆ្នោតដែលចង់ប្រើ
គេហទំព័របង្ហាញពី RAVBM អាចចូលទៅកាន់គេហទំព័រ www.stanvote.com សម្រាប់ការណែនាំ។

លើសពីនេះ ស្រោមសំបុត្រប្រគល់សន្លឹកឆ្នោតមកវិញដែលចេញឱ្យអ្នកបោះឆ្នោតមានការចូលបន្ទាប់
ដោយមានរង្វង់មូលពីរ។ ការចូលបន្ទាត់គឺជាការណែនាំសម្រាប់អ្នកបោះឆ្នោតដែលមើលមិនឃើញ
ដើម្បីកំណត់ទីតាំងហត្ថលេខា និងចុះហត្ថលេខានៅកន្លែងត្រឹមត្រូវ។

## ការស្នើសុំសន្លឹកឆ្នោតជំនួស

§4005(a)(10)(I)(ii)

អ្នកបោះឆ្នោតដែលជាជនពិការអាចស្នើសុំសន្លឹកឆ្នោតជំនួសតាមវិធីបីយ៉ាង៖ (1) តាមសំបុត្រ ឬ
(2) ការហៅទៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus (209-525-5201) ទូរសព្ទ TTY
(3) ដោយការទៅមជ្ឈមណ្ឌលបោះឆ្នោតណាមួយ។ អ្នកបោះឆ្នោតដែលចង់ស្នើសុំសន្លឹកឆ្នោតជំនួសបោះ
តាមសំបុត្រ អាចស្នើសុំបានដោយធ្វើតាមការណែនាំ នៅលើស្រោមសំបុត្រ ដោយគូសសម្គាល់លើប្រអ
ប់ខូចនៅលើសន្លឹកឆ្នោត ហើយប្រគល់ស្រោមសំបុត្រទៅវិញ។ ការប្ដូរសន្លឹកឆ្នោតបោះតាមសំបុត្រចុ
ងក្រោយអាចត្រូវបានផ្ញើតាមសំបុត្រនៅប្រាំពីរថ្ងៃមុនថ្ងៃបោះឆ្នោត។ អ្នកបោះឆ្នោតដែលជាជនពិការ
ក៏អាចទៅមជ្ឈមណ្ឌលបោះឆ្នោតដើម្បីទទួលបានសន្លឹកឆ្នោតជំនួស ឬគូសសន្លឹកឆ្នោតដោយប្រើប្រា

DRAFT

ស់ឧបករណ៍សម្រាប់ជនពិការ។ លេខទូរសព្ទ TTY នឹងត្រូវផ្សព្វផ្សាយនៅលើវិបសាយរបស់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus និងនៅលើសម្ភារបោះឆ្នោតដែលបានផ្ញើទៅអ្នកបោះឆ្នោត។

## ទូរសព្ទឥតគិតថ្លៃសម្រាប់អ្នកបោះឆ្នោតថ្លង់ ឬស្ដាប់មិនសូវឮ

§4005(a)(10)(I)(vii)
ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus មានទូរសព្ទ TTY ឥតគិតថ្លៃសម្រាប់អ្នកបោះឆ្នោតដែលថ្លង់ ឬស្ដាប់មិនសូវឮ ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ៖ ម៉ោង 8:00 ព្រឹក – 5:00 ល្ងាច និង 7:00 ព្រឹក – 8:00 យប់នៅថ្ងៃបោះឆ្នោត។ ទូរសព្ទ TTY ឥតគិតថ្លៃ នឹងត្រូវផ្សព្វផ្សាយនៅលើវិបសាយរបស់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus និងនៅលើសម្ភារបោះឆ្នោតដែលបានផ្ញើទៅអ្នកបោះឆ្នោត។

## ការដោះស្រាយកម្លាតក្នុងពិការភាពរបស់អ្នកបោះឆ្នោត និងការចូលរួម

§4005(a)(10)(I)(iii)
ក្រោយពេលបោះឆ្នោតម្ដងៗ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងព្យាយាមដោះស្រាយបញ្ហាគម្លាតធំៗនៅក្នុងលទ្ធភាពចូលបោះឆ្នោតរបស់ជនពិការ និងការចូលរួមរបស់ជនពិការ។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងជួបជាមួយ VAAC ដើម្បីពិភាក្សាអំពីបញ្ហា និងរកដំណោះស្រាយដើម្បីបម្រើអ្នកបោះឆ្នោតដែលជាជនពិការកាន់តែប្រសើរឡើង។ លើសពីនេះ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត នឹងធ្វើការរាយការណ៍អំពីលទ្ធផលជាមួយនឹងបុគ្គលមជ្ឈមណ្ឌលបោះឆ្នោតទាំងអស់ ដើម្បីវាយតម្លៃនិងដោះស្រាយឱកាស ដើម្បីកែលម្អការចូលរួមរបស់អ្នកបោះឆ្នោតដែលជាជនពិការឲ្យបានកាន់តែប្រសើរឡើងថែមទៀត។

## ជំពូក VII - ការអប់រំ និងការផ្សព្វផ្សាយដល់អ្នកបោះឆ្នោត – សហគមន៍ជនជាតិភាគតិចផ្នែកភាសា

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus បានបង្កើតគណៈកម្មការប្រឹក្សាយោបល់លទ្ធភាពចូលប្រើប្រាស់បានផ្នែកភាសា (LAAC) ដើម្បីស្វែងរកវិធីសាស្ត្រល្អបំផុតក្នុងការអប់រំ និងផ្សព្វផ្សាយដល់ជនដែលមានតម្រូវការផ្នែកភាសាអាសារៀន ភាសាខ្មែរ ពុនចាប៊ី ទាក់ទងនឹង VCA។ សមាជិកគណៈកម្មការកំពុងត្រូវបានជ្រើសរើសដោយផ្អែកលើការចូលរួមរបស់ពួកគេនៅក្នុងសហគមន៍ដែលមានតម្រូវការក្នុងការចេញចូល។ សមាជិកបច្ចុប្បន្នគឺជាផ្នែកមួយនៃអង្គការសហគមន៍ដែលតំណាង និងផ្តល់ជំនាញលើសហគមន៍ភាសាដែលខោនធីផ្តល់ជំនួយ។ អង្គការសហគមន៍រួមមាន ក្លឹបពលរដ្ឋអាស៊ីរៀនអាមរិក, El Concilio, Jakara Movement និង ធនធានសហគមន៍អាស៊ីអាមេរិក Stanislaus។

គោលបំណងនៃគណៈកម្មការប្រឹក្សាយោបល់លទ្ធភាពចូលប្រើប្រាស់បានផ្នែកភាសា (LAAC) គឺដើម្បីផ្តល់ដំបូន្មាន និងជួយដល់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus ក្នុងការកែលម្អដំណើរការបោះឆ្នោតសម្រាប់អ្នកបោះឆ្នោតដែលចេះអង់គ្លេសបន្តិចបន្តួចស្របទៅតាមប្រការនៃច្បាប់បោះឆ្នោតបច្ចុប្បន្ន។

- សមាជិក LAAC នឹងជួយឲ្យខោនធីអាចបន្តរកឃើញវិធីកាន់តែមានប្រសិទ្ធភាពដើម្បីអប់រំអ្នកបោះឆ្នោតនៅតាមសហគមន៍ដែលចេះអង់គ្លេសបន្តិចបន្តួច។
- LAAC ផ្តល់សាធារណជននូវវេទិកាដើម្បីផ្តល់អនុសាសន៍អំពីរបៀបកែលម្អលទ្ធភាពទទួលបានសម្ភារបោះឆ្នោត។
- សមាជិក LAAC នឹងជួយក្នុងការពិនិត្យមើលសម្ភារបោះឆ្នោតនិងការអប់រំអ្នកបោះឆ្នោត ដើម្បីធានាភាពច្បាស់លាស់សម្រាប់អ្នកបោះឆ្នោតដែលចេះអង់គ្លេសបន្តិចបន្តួច។
- សមាជិក LAAC នឹងជួយជ្រើសរើស និងរក្សាទុកបុគ្គលិកដែលប្រើពីរភាសា។
- សមាជិក LAAC អាចផ្តល់អនុសាសន៍អំពីការកែលម្អទម្រង់ការដែលនឹងត្រូវពិចារណាសម្រាប់ការអនុម័តដោយការិយាល័យចុះបញ្ជីអ្នកបោះឆ្នោត។

សាធារណៈជនដែលមានចំណាប់អារម្មណ៍ និងមានការប្តេជ្ញាចិត្តត្រូវបានលើកទឹកចិត្តឱ្យចូលរួមជាមួយ VAAC។ សម្រាប់ព័ត៌មានអំពីរបៀបដាក់ពាក្យ សូមចូលទៅកាន់គេហទំព័រ www.stanvote.com។

### ការអប់រំសហគមន៍ជនជាតិភាគតិចផ្នែកភាសា - សិក្ខាសាលាអប់រំអ្នកបោះឆ្នោត

§4005(a)(10)(I)(i)(VI)(ia)

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងផ្តល់ការបង្ហាញអំពីព័ត៌មានម៉ូដែលរបស់មជ្ឈមណ្ឌលបោះឆ្នោតដោយផ្ទាល់ទៅអ្នកបោះឆ្នោត និងអ្នកចូលរួមនៅតាមបណ្តាព្រឹត្តិការណ៍នានា ។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus មានគោលដៅសម្របសម្រួលជាមួយដៃគូសហគមន៍ LAAC និង VAAC ដើម្បីកំណត់អត្តសញ្ញាណឱកាសដើម្បីអប់រំដល់អ្នកបោះឆ្នោតរបស់យើង ផ្តល់ការបង្ហាញអំពីឧបករណ៍បោះឆ្នោត និងពន្យល់អំពីរបៀបស្នើសុំ និងទទួលបានសន្លឹកឆ្នោតភាសាជនជាតិភាគតិច។ សិក្ខាសាលាអប់រំបន្ថែមទៀតនឹងត្រូវធ្វើឡើងមុនការបោះឆ្នោតដែលបានកំណត់ពេល ដែលអនុញ្ញាតឱ្យអ្នកបោះឆ្នោតទទួលបានព័ត៌មានជាមុននៅពេលពួកគេគិតអំពីការបោះឆ្នោត។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងខិតខំផ្សព្វផ្សាយនៅតាមតំប

ន់នីមួយៗនៅក្នុងខោនធី។ អ្នកបោះឆ្នោតនឹងមានឱកាសជាច្រើនដើម្បីស្វែងយល់អំពីម៉ូដែលរបស់មជ្ឈមណ្ឌលបោះឆ្នោត និងជម្រើសបោះឆ្នោតតាមភាសារបស់ពួកគេ ជាអាទិ៍រួមមានដូចជាៈ

1) VAAC និង LAAC របស់នាយកដ្ឋាន
    a. ការប្រជុំរួមមានការបង្ហាញអំពីប្រព័ន្ធបោះឆ្នោត និងបច្ចុប្បន្នភាពផ្នែកព័ត៌មាន
    b. បង្កើតសម្ភារអប់រំជាមួយ VAAC និង LAAC ដើម្បីចែកចាយដល់សមគមន៍របស់ពួកគេ

2) ការបង្ហាញដល់ទស្សនិកជនផ្សេងៗៈ
    a. ក្រុមប្រឹក្សាភិបាលនៃអ្នកដឹកនាំនៃខោនធី
    b. សាលាក្រុងរបស់មន្ត្រីជាប់ឆ្នោត
    c. គណៈកម្មការមជ្ឈឹមខោនធី និងគណៈកម្មការនយោបាយ
    d. ស្មៀនក្រុង
    e. សហគមន៍ភាសា
    f. អង្គការផ្តល់សេវាកម្ម (ដូចជា Rotary, Kiwanis)

## កិច្ចប្រជុំពិគ្រោះយោបល់សាធារណៈ

§4005(a)(10)(I)(i)(VI)(ia)

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងបើកកិច្ចប្រជុំពិគ្រោះយោបល់ដល់សាធារណៈជនដែលប្រើពីរភាសាសម្រាប់ EAP ដែលបានស្នើឡើង សម្រាប់ភាសាដែលត្រូវការចាំបាច់ប្រចាំសហព័ន្ធនិងរដ្ឋនៅក្នុងខោនធី Stanislaus។ នៅពេលរៀបចំភាសាចាំបាច់របស់ផែនការ Stanislaus នេះ ភាសាផ្សេងក្រៅពីអង់គ្លេស មានដូចជាអេស្ប៉ាញ ពុនចាប៊ី ខ្មែរ និងអាសារៀន។

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតខោនធី Stanislaus នឹងផ្តល់ឱកាសសម្រាប់សហគមន៍ភាសារបស់ខោនធី ដើម្បីទទួលព័ត៌មានអំពីសម្ភារ និងជំនួយដែលមានជាភាសារបស់ពួកគេ បន្ថែមពីលើដំណើរការបោះឆ្នោតនៃម៉ូដែលនៅមជ្ឈមណ្ឌលបោះឆ្នោត។ គ្រប់សិក្ខាសាលានឹងមានអ្នកបកប្រែភាសាជាក់លាក់ដើម្បីជួយដល់អ្នកចូលរួម។ ព័ត៌មានអំពីព្រឹត្តិការណ៍សិក្ខាសាលានឹងត្រូវបានប្រកាសយ៉ាងតិច 10 ថ្ងៃមុនពេលប្រជុំចាប់ផ្តើម ហើយបានបង្ហោះនៅលើគេហទំព័រ www.stanvote.com ក្រោមផ្នែក "សេចក្តីដំណឹងសាធារណៈ"។ កិច្ចប្រជុំទាំងនេះក៏មានរាយផងដែរក្នុងឧបសម្ព័ន្ធ A។

## ប្រព័ន្ធផ្សព្វផ្សាយ និងការប្រកាសអំពីសេវាកម្មសាធារណៈ

§4005(a)(10)(I)(i)(I), §4005(a)(10)(I)(i)(IX)

ការិយាល័យចុះបញ្ជីអ្នកបោះឆ្នោតរបស់ខោនធី Stanislaus នឹងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗតាមទម្រង់ជាពីរភាសា ដើម្បីអប់រំដល់សាធារណៈជននៅក្នុងខោនធី Stanislaus ដើម្បីផ្សព្វផ្សាយអំពីវត្តមាននៃសេចក្តីចម្លងដែលបានបកប្រែរួចនៃសន្លឹកឆ្នោតផ្លូវការជាភាសាអាសារៀន ខ្មែរឬ ពុនចាប៊ី និងរបៀបស្នើសុំសន្លឹកឆ្នោត។ ជម្រើសសម្រាប់ជនពិការក៏នឹងមានផ្តល់ជាទម្រង់នេះផងដែរ។ ប្រព័ន្ធផ្សព្វផ្សាយ ជាអាទ៍រួមមានៈ

i) កាសែតៈ (Latino Times)
ii) ទូរទស្សន៍ៈ (Assyrian TV)
ii) វិទ្យុៈ (KBDG-FM 90.9 Assyrian Radio)
iii) ប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គម វិបសាយរបស់នាយកដ្ឋាន ហ្វេសប៊ុករបស់ខោនធី Stanislaus
iv) នាយកដ្ឋានខោនធី
v) ការប្រកាសអំពីសេវាកម្មសាធារណៈ

ការខិតខំប្រែងប្រែងធំៗសម្រាប់អប់រំដល់មនុស្សដែលអាចបោះឆ្នោតបាន នឹងត្រូវបានធ្វើឡើងនៅតាមប្រព័ន្ធផ្សព្វផ្សាយនៅខាងលើ។ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងបន្តគាំទ្រដល់សាធារណៈជន និងនឹងកំណត់ពេលវេលាប្រាស្រ័យទាក់ទង នៅពេលខិតជិតដល់កាលបរិច្ឆេទបោះឆ្នោតសំខាន់ៗ។ នៅពេលផែនការនេះត្រូវបានបោះពុម្ពផ្សាយ នាយកដ្ឋានរបស់យើងកំពុងទទួលបានជំនួយពីសមាជិក LAAC ដែលតំណាងឱ្យសហគមន៍និយាយភាសាអាស៊ីរៀន ពុនចាប៊ី និងអេស្ប៉ាញ ដើម្បីផ្តល់ការប្រកាសអំពីសេវាសាធារណៈតាមរយៈវិទ្យុ។

## ជំនួយតាមទូរសព្ទបន្ទាន់ឥតគិតថ្លៃសម្រាប់អ្នកបោះឆ្នោត

§4005(a)(10)(I)(vii)
ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតខោនធី Stanislaus នឹងផ្តល់ជំនួយផ្នែកភាសាតាមតម្រូវការតាមរយៈខ្សែទូរសព្ទជំនួយបន្ទាន់ឥតគិតថ្លៃសម្រាប់អ្នកបោះឆ្នោត។ ទូរសព្ទឥតគិតថ្លៃនេះនឹងមានដំណើរការ 29 ថ្ងៃ មុនពេលបោះឆ្នោតរហូតដល់ម៉ោង 5:00 ល្ងាចមួយថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។ លេខទូរសព្ទនេះនឹងត្រូវផ្សព្វផ្សាយនៅលើវិបសាយរបស់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus និងនៅលើសម្ភារបោះឆ្នោតដែលបានផ្ញើទៅអ្នកបោះឆ្នោត។

## សម្ភារអប់រំជាភាសាអេស្ប៉ាញ

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus នឹងចែកចាយសម្ភារអប់រំជាភាសាអេស្ប៉ាញដល់អ្នកបោះឆ្នោតតាមរយៈអង្គការដែលជ្រើសរើសជួយយើងនៅក្នុងកិច្ចប្រឹងប្រែងជួយរបស់យើង។ ការទាក់ទងទាំងនេះគឺជាការបន្ថែមពីលើការទាក់ទងចាំបាច់ផ្សេងទៀត ដូចជា សន្លឹកឆ្នោតគំរូ និងការផ្តល់ការបោះឆ្នោតតាមសន្លឹកឆ្នោតបោះតាមសំបុត្រ។

## ជំនួយផ្នែកភាសាមាននៅមជ្ឈមណ្ឌលបោះឆ្នោត

EC 14282
អនុញ្ញាតឱ្យអ្នកបោះឆ្នោតមានមនុស្សនៅជាមួយរហូតដល់ពីរនាក់ជួយពួកគេក្នុងការគូសសន្លឹកឆ្នោត។ អ្នកបោះឆ្នោតដែលមានតម្រូវការជំនួយផ្នែកភាសា អាចនាំសមាជិកគ្រួសារ ឬមិត្តភក្តិមកជួយពួកគេនៅមណ្ឌលបោះឆ្នោត។ លើសពីនេះ នាយកដ្ឋានខិតខំដោយស្មោះត្រង់ក្នុងការជួល និងបណ្តុះបណ្តាលស្មៀនរៀបចំការបោះឆ្នោត និងអ្នកស្ម័គ្រចិត្តដែលចេះពីរភាសាជាភាសាអេស្ប៉ាញ អាស៊ីរៀន ខ្មែរ និងពុនចាប៊ី ដើម្បីឱ្យបម្រើនៅមជ្ឈមណ្ឌលបោះឆ្នោត។ ស្មៀនរៀបចំការបោះឆ្នោត និងអ្នកស្ម័គ្រចិត្តត្រូវចូលរួមវគ្គបណ្តុះបណ្តាលមុនពេលបម្រើនៅមជ្ឈមណ្ឌលបោះឆ្នោត។ វគ្គបណ្តុះបណ្តាលនេះរួមមានរបៀបជួយអ្នកបោះឆ្នោតចំពោះតម្រូវការជំនួយផ្នែកភាសា។

សេវាអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទក៏មាននៅគ្រប់មជ្ឈមណ្ឌលបោះឆ្នោតផងដែរ ក្នុងព្រឹត្តិការណ៍ដែលមិនមានបុគ្គលិកចេះពីរភាសា។ សេវាកម្មនេះត្រូវបានផ្តល់ជូនតាមរយៈរដ្ឋលេខាធិការនៃរដ្ឋ California។

អ្នកបោះឆ្នោតដែលត្រូវការជំនួយជាភាសាអាសារៀន ខ្មែរ និងពុនចាប៊ី ក៏អាចស្នើសុំសំណៅបកប្រែនៃសន្លឹកឆ្នោតផ្លូវការ ដែលហៅថា "សន្លឹកឆ្នោតទូរសារ" ផងដែរ។ សញ្ញាដែលបានបកប្រែត្រូវបានបង្ហោះជូនដំណឹងដល់អ្នកបោះឆ្នោតអំពីភាពអាចរកបាននៃសន្លឹកឆ្នោតតាមទូរសារ ហើយច្បាប់ចម្លងនៃសន្លឹកឆ្នោតតាមទូរសារក៏ត្រូវបានបង្ហោះផងដែរ។ សម្ភារបោះឆ្នោតផ្សេងទៀតដែលផ្តល់ជូនជាភាសាអាស៊ីរៀន ភាសាខ្មែរ និងពុនចាប៊ី រួមមាន មគ្គុទ្ទេសក៍សម្រាប់ព័ត៌មានអ្នកបោះឆ្នោតរបស់រដ្ឋដែលផលិតដោយរដ្ឋលេខាធិការរបស់រដ្ឋ California។

## ការស្នើសុំសន្លឹកឆ្នោតទូរសារភាសាភាគតិច

§4005(a)(10)(I)(i)(V)

មានវិធីបីយ៉ាងក្នុងការស្នើសុំសន្លឹកឆ្នោតទូរសារៈ

1) ប្រគល់កាតប៉ុស្តាល់ស្នើសុំសន្លឹកឆ្នោតទូរសារដោយការផ្ញើសំបុត្រទៅ 1021 “I” St., Modesto, CA 95354, ផ្ញើអ៊ីមែលទៅ stanvote@stancounty.com ឬទូរសារវាទៅ 209-525-5802
2) ទូរសព្ទទៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus និងស្នើសុំសន្លឹកឆ្នោតទូរសារ (209-525-5201)
3) ស្នើសុំសន្លឹកឆ្នោតទូរសារនៅមជ្ឈមណ្ឌលបោះឆ្នោតណាមួយនៅក្នុងខោនធី Stanislaus ឬទៅកាន់ការិយាល័យធំនៅ 1021 “I” St., Modesto

## ការកំណត់អត្តសញ្ញាណអ្នកបោះឆ្នោតភាគតិចផ្នែកភាសា

§4005(a)(10)(I)(i)(V)

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus កំណត់អត្តសញ្ញាណអ្នកបោះឆ្នោតភាគតិចផ្នែកភាសាតាមរយៈចំណង់ចំណូលចិត្តផ្នែកភាសារបស់ពួកគេដែលបានបញ្ជាក់នៅក្នុងទម្រង់ចុះឈ្មោះអ្នកបោះឆ្នោត។ អ្នកបោះឆ្នោតដែលប្រើភាសាភាគតិចក៏អាចអ៊ីមែល ឬទូរសព្ទទៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៅខោនធី Stanislaus ដើម្បីកំណត់ចំណង់ចំណូលចិត្តផ្នែកភាសារបស់ពួកគេ។ យើងប្រមូលនិងរក្សាទុកទិន្នន័យនេះនៅក្នុងប្រព័ន្ធគ្រប់គ្រងការបោះឆ្នោតរបស់យើង។ លើសពីនេះ យើងទទួលបានព័ត៌មានអំពីលក្ខខណ្ឌតម្រូវស្តីពីជំនួយផ្នែកភាសាពីរដ្ឋលេខាធិការ ដោយផ្អែកលើការស្ទង់មតិសហគមន៍អាមេរិករបស់ការិយាល័យជំរឿនសហរដ្ឋអាមេរិក។

DRAFT

# ឧបសម្ព័ន្ធ

DRAFT

# ឧបសម្ព័ន្ធ A

ព្រឹត្តិការណ៍អប់រំ និងការជួយដល់អ្នកបោះឆ្នោត

| កាលបរិច្ឆេទ | ស្ថាប័ន | ទីតាំង |
|---|---|---|
| 1/4/2021 | **គណៈកម្មាធិការកណ្តាលគណបក្សសាធារណរដ្ឋនៃខោនធី Stanislaus** | 118 W. Orangeburg Ave. Modesto, CA |
| 2/8/2021 | **Assyrian TV និង KBDG-RM 90.9 MHz** | Zoom |
| 2/9/2021 | **Modesto Republican Women** | 945 McHenry Ave. Modesto, CA |
| 2/11/2021 | **ក្រុមប្រឹក្សាភិបាលអចលនទ្រព្យ Oakdale** | House of Beef – 201 N. 3rd. Ave. Oakdale, CA |
| 2/25/2021 | **ទីភ្នាក់ងារធនធានជនពិការសម្រាប់ការរស់នៅឯករាជ្យ** | បទសម្ភាសន៍តាមទូរសព្ទ |
| 3/24/2021 | **សមាគមអចលនទ្រព្យសិនត្រល វ៉ាលី** | Zoom |
| 4/16/2021 | **បទបង្ហាញ VCA<br>សម្រាប់ក្រុមប្រឹក្សាភិបាលនៃអ្នកដឹកនាំ** | 1021 I Street |
| 4/19/2021 | **បទបង្ហាញ VCA<br>សម្រាប់ក្រុមប្រឹក្សាភិបាលនៃអ្នកដឹកនាំ** | 1021 I Street |
| 4/20/2021 | **បទបង្ហាញ VCA<br>សម្រាប់ក្រុមប្រឹក្សាភិបាលនៃអ្នកដឹកនាំ** | 1021 I Street |
| 4/22/2021 | **ចំណងជើងកិច្ចប្រជុំក្រុមហ៊ុន** | Zoom |
| 4/26/2021 | **ក្រុមប្រឹក្សាភិបាលនៃអ្នកដឹកនាំ<br>បទបង្ហាញ VCA** | 1021 I Street |
| 5/3/2021 | **គណៈកម្មាធិការកណ្តាលគណបក្សសាធារណរដ្ឋនៃខោនធី Stanislaus** | 118 W. Orangeburg Ave. Modesto, CA |
| 5/12/2021 | **ស្មៀនក្រុង** | Zoom |
| 5/17/2021 | **2nd Harvest/United Way** | Zoom |
| 5/26/2021 | **គណៈកម្មាធិការកណ្តាលប្រជាធិបតេយ្យ** | Zoom |
| 6/8/2021 | **Kiwanis of Modesto<br>បទបង្ហាញ VCA** | Papapolloni Mediterranean Bistro-<br>2501 McHenry Ave. Modesto, CA |
| 6/9/2021 | **Oakdale Rotary<br>បទបង្ហាញ VCA** | Oakdale Golf & Country Club<br>243 N. Stearns Rd. Oakdale, CA |
| 6/10/2021 | **Kiwanis – North Modesto** | Grafitti Museum<br>9th & Coldwell<br>Modesto/ Zoom Hybrid |
| 6/16/2021 | **United Way** | Zoom |
| 6/21/2021 | **កិច្ចប្រជុំណែនាំ VAAC EAP** | Zoom |
| 6/22/2021 | **កិច្ចប្រជុំណែនាំ LAAC EAP** | Zoom |
| 7/8/2021 | **Sunrise Rotary** | Green's - 953 10th Street, Modesto |
| 7/14/2021 | **ក្រុង Oakdale** | House of Beef - 201 N. 3rd Ave. Oakdale, CA |

DRAFT

| កាលបរិច្ឆេទ | ស្ថាប័ន | ទីតាំង |
|---|---|---|
| 7/22/2021 | **Newman Rotary** | Pizza Plus - 1420 Main Street Newman, CA |
| 7/31/2021 | **កិច្ចប្រជុំពិគ្រោះយោបល់សាធារណៈ EAP** | El Concilio - 1314 H Street Modesto, CA Hybrid Zoom |
| 8/4/2021 | **ចំណាងជើងកិច្ចប្រជុំក្រុមហ៊ុន** | Veterans Center3500 Coffee Rd. Modesto, CA |
| 8/6/2021 | **Salida Rotary** | 2832 Healthcare Way Modesto, CA |
| 8/12/2021 | **Ceres Courier** | បទសម្ភាសន៍តាមទូរសព្ទ |
| 8/14/2021 | **កិច្ចប្រជុំពិគ្រោះយោបល់សាធារណៈ EAP** | Harvest Hall - 3800 Cornucopia Way Modesto, CA |
| 8/17/2021 | **ការពិគ្រោះយោបល់ EAP សម្រាប់អាស៊ីរៀន** | Assyrian American Civic Club – 2618 N. Golden State Blvd. Turlock, CA |
| 8/19/2021 | **Turlock Journal** | បទសម្ភាសន៍តាមទូរសព្ទ |
| 8/20/2021 | **Patriots** | Ridgeways 2401 E. Orangeburg Ave. Modesto, CA |
| 8/20/21 | **KCRA – Channel 3** | អ៊ីមែល និងទូរសព្ទ |
| 8/27/2021 | **Turlock Kiwanis** | Crostini Restaurant 811 W. Hawkeye Turlock, CA |
| 9/1/2021 | **កិច្ចប្រជុំពិគ្រោះយោបល់សាធារណៈ EAP** | King Kennedy Center 601 Martin Luther King Dr., Modesto, CA |
| 9/1/2021 | **Turlock Sunrise Rotary Club** | Toscana's Ristorante 1801 Colorado Ave. #190 Turlock, CA |
| 9/11/2021 | **Federation of the Blind** | Zoom |
| 9/23/2021 | **Oakdale Lions Club** | Oakdale Pavilion 151 S. Sierra Ave. Oakdale, CA |
| 10/6/2021 | **កិច្ចប្រជុំពិគ្រោះយោបល់សាធារណៈ EAP** | Ceres American Legion Hall 2609 Lawrence St. Ceres, CA 95307 |
| 01/6/2022 | **ក្រុង Riverbank សិក្ខាសាលាអប់រំអ្នកបោះឆ្នោត** | St. Frances of Rome Church 2827 Topeka St, Riverbank CA |
| 01/11/2022 | **ក្រុង Turlock សិក្ខាសាលាអប់រំអ្នកបោះឆ្នោត** | Turlock Library, Community Room 550 N. Minaret Ave., Turlock CA |
| 01/12/2022 | **ក្រុង Waterford សិក្ខាសាលាអប់រំអ្នកបោះឆ្នោត** | Waterford Community Center 540 C Street, Waterford CA |
| 01/18/2022 | **ក្រុង Newman សិក្ខាសាលាអប់រំអ្នកបោះឆ្នោត** | L.J. Newman Memorial Building 649 Orestimba Rd., Newman CA |
| 01/19/2022 | **ក្រុង Modesto សិក្ខាសាលាអប់រំអ្នកបោះឆ្នោត** | Stanislaus Veterans Center, Banquet Hall 3500 Coffee Rd., Modesto CA |

DRAFT

| កាលបរិច្ឆេទ | ស្ថាប័ន | ទីតាំង |
|---|---|---|
| 01/25/2022 | **ទីក្រុង Ceres**<br>**សិក្ខាសាលាអប់រំអ្នកបោះឆ្នោត** | Ceres American Legion Hall<br>2609 Lawrence St., Ceres CA |
| 01/31/2022 | **ក្រុង Oakdale**<br>**សិក្ខាសាលាអប់រំអ្នកបោះឆ្នោត** | Gene Bianchi Community Center<br>110 S 2nd Ave., Oakdale CA |
| 02/01/2022 | **ក្រុង Hughson**<br>**សិក្ខាសាលាអប់រំអ្នកបោះឆ្នោត** | Hughson Community Senior Center<br>Hughson<br>2307 4th Street, Hughson CA |
| 02/08/2022 | **ទីក្រុង Patterson**<br>**សិក្ខាសាលាអប់រំអ្នកបោះឆ្នោត** | City of Patterson City Hall,<br>Board Chambers<br>1 Plaza, Patterson, CA |

ចូលទៅកាន់គេហទំព័រ stanvote.com ដើម្បីទទួលបានបញ្ជីព្រឹត្តិការណ៍ថ្មីៗ។

DRAFT

# ឧបសម្ព័ន្ធ B

ផែនទីនៃមជ្ឈមណ្ឌលបោះឆ្នោតដែលប្រើសម្រាប់ការបោះឆ្នោតដកតំណែងអភិបាលរដ្ឋ California ឆ្នាំ 2021



# ឧបសម្ព័ន្ធ C

ការរៀបចំគំរូនៃប្លង់មជ្ឈមណ្ឌលបោះឆ្នោត



# ឧបសម្ព័ន្ធ D

ផែនទីទីតាំងទម្លាក់សន្លឹកឆ្នោតដែលប្រើសម្រាប់ការបោះឆ្នោតដកតំណែងអភិបាលរដ្ឋ California ឆ្នាំ 2021



# ឧបសម្ព័ន្ធ E

## តម្លៃប៉ាន់ស្មាន និងការប្រៀបធៀប

| **ប្រភេទ** | **ការចំណាយជាក់ស្តែងជាមួយនឹងការស្ទង់មតិ ការបោះឆ្នោតបឋម ឆ្នាំ 2018** | **តម្លៃប៉ាន់ស្មានជាមួយនឹងមជ្ឈមណ្ឌលបោះឆ្នោត ការបោះឆ្នោតបឋម ឆ្នាំ 2022** |
|---|---|---|
| កម្លាំងពលកម្ម | | |
| បុគ្គលិករៀបចំការបោះឆ្នោត - ពេញម៉ោង និងក្រៅម៉ោង | $275,459.27 | $496,608.41 |
| អ្នកស្ម័គ្រចិត្ត | $64,871.55 | $65,000.00 |
| សម្ភារផ្គត់ផ្គង់ និងឧបករណ៍សម្រាប់ការបណ្តុះបណ្តាល | គ្មាន | $1,875.00 |
| ការបោះពុម្ព | | |
| ការរៀបចំការបោះឆ្នោត និងសន្លឹកឆ្នោត | $17,962.13 | $6,500.00 |
| ការបោះឆ្នោតដោយសន្លឹកឆ្នោតផ្ញើតាមសំបុត្រ | $171,699.16, | $745,033.00 |
| សន្លឹកឆ្នោតតាមតំបន់ / សន្លឹកឆ្នោតមជ្ឈមណ្ឌលបោះឆ្នោត | $48,025.80 | $7,272.00 |
| មគ្គុទ្ទេសក៍ព័ត៌មានសម្រាប់អ្នកបោះឆ្នោត | $155,356.34 | $559,208.00 |
| ស្រោមសំបុត្រ | $9,816.63 | $52,513.55 |
| សម្ភារផ្សេងៗសម្រាប់ការបោះឆ្នោត ឬអ្នកបោះឆ្នោត (ផ្លាកសញ្ញា ទម្រង់បែបបទបោះពុម្ពផ្សាយ។ល។) | $6,945.80 | $9,248.00 |
| កន្លែងបោះឆ្នោត / មជ្ឈមណ្ឌលបោះឆ្នោត | | |
| ថ្លៃជួលកន្លែង និងថ្លៃសេវាថែទាំ | $2,180.00 | $21,500.00 |
| ការដឹកជញ្ជូន | $20,020.00 | $18,000.00 |
| សម្ភារផ្គត់ផ្គង់ | $7,374.14 | $12,500.00 |
| ការជួលយានយន្ត | $2,383.64 | $8,000.00 |
| ការផ្តល់អាជ្ញាបណ្ណការតភ្ជាប់ និងឧបករណ៍។ល។ | គ្មាន | $23,500.00 |
| សំបុត្រ / ប្រៃសណីយ៍ | $183,849.23 | $435,045.00 |
| សន្តិសុខ | $1,339.25 | $1,400.00 |
| លទ្ធភាពការបោះឆ្នោតតាមសំបុត្រពីចម្ងាយ | គ្មាន | $12,450.00 |
| សេវាកម្មបកប្រែ | $9,552.43 | $10,000.00 |
| ការអប់រំសហគមន៍ | គ្មាន | $100,000 |
| ការចំណាយសរុប | $976,835.37 | $2,587, 440.96 |

| ប្រភេទនៃការបោះឆ្នោត | ការបោះឆ្នោតបឋម ឆ្នាំ 2018 **ចំនួននៃទីតាំងបោះឆ្នោតតម្រូវឱ្យមាន** | ការបោះឆ្នោតបឋម ឆ្នាំ 2022 (រួមបញ្ចូលកំណើនប៉ាន់ស្មាន) **ចំនួននៃទីតាំងបោះឆ្នោត** | ការបោះឆ្នោតបឋម ឆ្នាំ 2018 **ចំនួនអ្នកស្ម័គ្រចិត្ត** | ការបោះឆ្នោតបឋម ឆ្នាំ 2022 **ចំនួនអ្នកស្ម័គ្រចិត្ត និងបុគ្គលិក** |
|---|---|---|---|---|
| គំរូកន្លែងបោះឆ្នោត | **145**<br>កំណត់សម្គាល់៖ ការបោះឆ្នោតមួយចំនួនត្រូវបានបម្រើជាការបោះឆ្នោតពីរដង ឬបីដង ដោយបម្រើដល់បរិវេណជាច្រើន។ | **150** | 594 | 600 |
| គំរូមជ្ឈមណ្ឌលបោះឆ្នោត | **23** | **28** | **140** | **300** |

DRAFT